# ម៉ូឌុល ៤
## តម្រាសម្រាប់អ្នកសម្របសម្រួល

### វគ្គបេសកកម្មពហុគុណ
ការដាំក្រុមជំនុំដែលមានសុខភាពល្អ

revised 3/4/19

# បេសកកម្មពហុគុណ
## ទិដ្ឋភាពទូទៅនៃកម្មវិធីសិក្សាអំពីការដាំក្រុមជំនុំ

| | ម៉ូឌុល ១<br>ការដាំក្រុមជំនុំ<br>ដែលមានសុខភាពល្អ | ម៉ូឌុល ២<br>ការត្រៀមរៀបចំដើម្បី<br>ចែកចាយដំណឹងល្អ | ម៉ូឌុល ៣<br>ការយល់ដឹងផែនការ<br>របស់ព្រះ | ម៉ូឌុល ៤<br>ការចែកចាយ<br>ដំណឹងល្អ | ម៉ូឌុល ៥<br>នាំមនុស្សឆ្ពោះ<br>ទៅរកជំនឿ | ម៉ូឌុល ៦<br>ការធ្វើឲ្យសិស្ស<br>រីកចម្រើន |
|---|---|---|---|---|---|---|
| ការចាប់ផ្ដើមជាមួយព្រះ | គ្រឹះនៅក្នុងព្រះគម្ពីរសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ | គ្រឹះខាងទេវសាស្ត្រសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ | គ្រឹះខាងបេសកកម្មសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ | គ្រឹះយុទ្ធសាស្ត្រសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ | ការរស់នៅតាមដំណឹងល្អ | ការរីកចម្រើនរបស់គ្រិស្តបរិស័ទ: ព្រះគ្រិស្តជាចំណុចផ្ដោតអារម្មណ៍ (ឬព្រះគ្រិស្តជាចំណុចប្រសព្វ) |
| ម៉ោងទី ១ | តើក្រុមជំនុំដែលមានសុខភាពល្អមានន័យយ៉ាងដូចម្ដេច? | ការធ្វើផែនទីខាងវិញ្ញាណ: គោលការណ៍នៃការស្រាវជ្រាវ | អ្វីដែលព្រះកំពុងតែបង្ហាញខ្ញុំ: ការចែកចាយការស្រាវជ្រាវរបស់លោកអ្នក | ការប្រោសឲ្យបានសុចរិតដោយសារជំនឿ | ឧបសគ្គរារាំងដល់ការផ្សាយដំណឹងល្អ | មហាបេសកកម្ម និងការដាំក្រុមជំនុំ |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | បេសកកម្ម អត្ថបទ និងបរិបទ | និមិត្ត អត្ថបទ និងបរិបទ | ត្រូវបានបញ្ជាក់នៅក្នុងការត្រាស់ហៅរបស់ព្រះ | ការផ្សាយដំណឹងល្អ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស |
| ម៉ោងទី ២ | តើអ្នកដាំក្រុមជំនុំដែលមានសុខភាពល្អមានន័យយ៉ាងដូចម្ដេច? | នេះជាអ្វីដែលព្រះយេស៊ូបានធ្វើសម្រាប់ខ្ញុំ! ការអភិវឌ្ឍន៍ និងការចែកចាយទីបន្ទាល់ផ្ទាល់ខ្លួន | អ្វីដែលព្រះកំពុងតែបង្ហាញខ្ញុំ: ការចែកចាយទីបន្ទាល់របស់លោកអ្នក និងការដើរអធិស្ឋាន | គោលការណ៍ដឹកនាំនៅក្នុងព្រះគម្ពីរ | ដំណើរការនៃការប្រែចិត្ត I | គន្លឹះទៅរកភាពជោគជ័យក្នុងការបង្កើតសិស្ស |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | បញ្ជាក់អះអាងនៅក្នុងការត្រាស់ហៅរបស់ព្រះ | ការផ្សាយដំណឹងល្អ | និមិត្ត អត្ថបទ និងបរិបទ | ពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការផ្សាយដំណឹងល្អ | ការបង្កើតសិស្ស |
| ម៉ោងទី ៣ | ការគិត «អ»<br>តើព្រះជាម្ចាស់ចង់បានអ្វី? | ការដឹកនាំក្រុមតូច | ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: ការសង្កេតស្គាល់និមិត្តរបស់ព្រះ | ការផ្សាយដំណឹងល្អ និងការដាំក្រុមជំនុំ | ដំណើរការនៃការប្រែចិត្ត II | ស្គាល់គោលដៅរបស់លោកអ្នក ស្គាល់មនុស្សរបស់លោកអ្នក |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ ការបង្កើតសិស្ស និងការពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ | ការផ្សាយដំណឹងល្អ | ការបង្កើតសិស្ស |
| ម៉ោងទី ៤ | រង្វង់នៃការដាំក្រុមជំនុំ | វិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសានុមាន II: ការសង្កេតមើលព្រះបន្ទូល | ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: ការកំណត់បេសកកម្ម | ការចាប់ផ្ដើមក្រុមតូច | ការផ្សាយដំណឹងល្អក្រុមតូច | វិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសានុមាន IV: ការអនុវត្តន៍ព្រះបន្ទូល |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស | ការផ្សាយដំណឹងល្អ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស |
| ម៉ោងទី ៥ | ហេតុអ្វីក្រុមតូច? | របៀបបំផុសការអធិស្ឋានសម្រាប់ក្រុមជំនុំដែលលោកអ្នកបានដាំ | ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: ការកំណត់គុណតម្លៃ | ការផ្សាយដំណឹងល្អ និងការបំពេញសេចក្ដីត្រូវការរបស់សហគមន៍ | ការអនុវត្តន៍៖ បទពិសោធន៍ក្រុមតូច | ការយល់ដឹងអំពីគតិលោក |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស | ការផ្សាយដំណឹងល្អ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការបម្រើ | ការផ្សាយដំណឹងល្អ | បញ្ជាក់អះអាងនៅក្នុងការត្រាស់ហៅរបស់ព្រះ |
| ម៉ោងទី ៦ | វិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសានុមាន: អនុញ្ញាតឲ្យព្រះគម្ពីរបង្រៀនយើង | វិធានស្ដីអំពីការអធិស្ឋានទំនុកដម្កើង ៩៥ | ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: ការកំណត់យុទ្ធសាស្ត្រ | វិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសានុមាន III: ការបកស្រាយព្រះបន្ទូល | ការធ្វើបទបង្ហាញផែនការមេ | វិធានស្ដីអំពីការអធិស្ឋានអរព្រះគុណដល់ព្រះសម្រាប់សេចក្ដីស្មោះត្រង់របស់ព្រះអង្គ |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស | ការថ្វាយបង្គំ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស | ការធ្វើសំយោគគំនិត | ការថ្វាយបង្គំ |

| | ម៉ូឌុល ៧<br>ការសង់ក្រុម | ម៉ូឌុល ៨<br>ការសង់ក្រុម | ម៉ូឌុល ៩<br>ការថែទាំមនុស្ស | ម៉ូឌុល ១០<br>ការបង្កើតឲ្យមានក្រុមជំនុំ | ម៉ូឌុល ១១<br>ការរៀបចំផែនការសម្រាប់ពេលអនាគត | ម៉ូឌុល ១២<br>ឆ្ពោះទៅមុខដោយការរួបរួម |
|---|---|---|---|---|---|---|
| ការចាប់ផ្តើមជាមួយព្រះ | ត្រូវបានបំផ្លាស់បំប្រែដោយសារដំណឹងល្អ | ព្រះគុណមានសម្រាប់អ្នកបន្ទាបខ្លួន | សេចក្តីស្រឡាញ់ គ្រឹះនៃព័ន្ធកិច្ច | ដើម្បីឲ្យលោកិយបានជឿ៖ យ៉ូហាន ១៧ | ការរាប់តម្លៃ | រហូតដល់លោកិយទាំងមូលញ្ញ! |
| ម៉ោងទី ១ | **គ្រឹះនៅក្នុងព្រះគម្ពីរសម្រាប់ក្រុមជំនុំ** | **ក្រុមការងារ: ការធ្វើការយ៉ាងមានប្រសិទ្ធភាពជាមួយអ្នកដទៃ** | **ការផ្សាយដំណឹងល្អតាមរយៈទំនាក់ទំនង** | **តួនាទីរួមរបស់ក្រុមជំនុំ** | **សេចក្តីផ្តើមអំពីភាពជាអ្នកមើលខុសត្រូវ** | **ការដោះស្រាយជម្លោះ** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការធ្វើសំយោគគំនិត | ការពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការថែទាំសមាជិកក្រុមតូច | ការធ្វើសំយោគគំនិត | ភាពជាអ្នកមើលខុសត្រូវលើធនធាន | ការប្រកបគ្នា |
| ម៉ោងទី ២ | **ក្រុមជំនុំ: សរីរាង្គដែលមានជីវិត** | **ការអភិវឌ្ឍន៍ក្រុម** | **ការប្រកបគ្នា** | **ព័ន្ធកិច្ចតាមរយៈអំណោយទានខាងវិញ្ញាណ** | **ភាពជាអ្នកមើលខុសត្រូវផ្នែកហិរញ្ញវត្ថុ** | **ការប្រែចិត្តជាមាគ៌ានៃជីវិត** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការធ្វើសំយោគគំនិត | ការពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការប្រកបគ្នា | ការបំពុសរូបកាយស្របទៅតាមអំណោយទានខាងវិញ្ញាណ | ភាពជាអ្នកមើលខុសត្រូវលើធនធាន | ការប្រកបគ្នា |
| ម៉ោងទី ៣ | **តើក្រុមមនុស្សក្លាយជាក្រុមជំនុំនៅពេលណា?** | **ភាពរស់រវើកនៃការពិភាក្សានៅក្នុងក្រុមតូច** | **ការថែទាំសហគមន៍របស់យើង** | **របៀបប្រើការស្វែងរកអំណោយទានខាងវិញ្ញាណ** | ការជួបជុំពិភាក្សាអំពី ការរៀបចំផែនការយុទ្ធសាស្ត្រ I | **ការប្រែចិត្ត និងការស្តារឡើងវិញ: វិន័យក្រុមជំនុំ** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការធ្វើសំយោគគំនិត | ការបង្កើតសិស្ស | ការផ្សាយដំណឹងល្អ អត្ថបទ និងបរិបទ | ការបំពុសរូបកាយស្របទៅតាមអំណោយទានខាងវិញ្ញាណ | | ការប្រកបគ្នា |
| ម៉ោងទី ៤ | **វិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសនុមាន V: របៀបប្រើការសិក្សាព្រះគម្ពីរបែបវិសេសនុមាន** | **ការហ្វឹកហ្វឺន អ្នកដឹកនាំថ្មីរបស់ក្រុមតូច** | **លក្ខណៈរបស់ក្រុមជំនុំដែលរីកចម្រើន** | **ភាពរស់រវើកនៃសង្គ្រាមខាងវិញ្ញាណ** | | **ការបញ្ជូនអ្នកដទៃឲ្យទៅធ្វើព័ន្ធកិច្ច** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការបង្កើតសិស្ស | ការបង្កើតសិស្ស ការពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការធ្វើសំយោគគំនិត | ការប្រកបគ្នា | | ការពង្រឹងសមត្ថភាពអ្នកដឹកនាំ |
| ម៉ោងទី ៥ | **ប្រវត្តិអ្នកដឹកនាំគ្រិស្តបរិស័ទ** | **របៀបទំនាក់ទំនង** | **ការដឹកនាំបែបបម្រើ** | **របៀបដឹកនាំក្រុមជំនុំនៅក្នុងការថ្វាយបង្គំ** | | **ក្រុមជំនុំរបស់យើង និងរូបកាយព្រះគ្រិស្តដែលធំជាង** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ពង្រឹងសមត្ថភាពអ្នកដឹកនាំ | ពង្រឹងសមត្ថភាពអ្នកដឹកនាំ | ពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការថ្វាយបង្គំ | | ការប្រកបគ្នា |
| ម៉ោងទី ៦ | **ការអធិប្បាយតាមព្រះគម្ពីរ I: ការយល់អំពីរាជសារ** | **ការអធិប្បាយតាមព្រះគម្ពីរ II: ការយល់អំពីអ្នកស្តាប់** | **វិធានស្តីអំពីការអធិស្ឋាន: អេភេសូរ ៣–៥** | **ការអធិប្បាយតាមព្រះគម្ពីរ III: ការយល់អំពីខ្លួនឯង** | | **វិធានស្តីអំពីការអធិស្ឋាន: អធិស្ឋានដើម្បីផ្សព្វផ្សាយដំណឹងល្អ** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការថ្វាយបង្គំ | ការថ្វាយបង្គំ | ការប្រកបគ្នា | ការថ្វាយបង្គំ | ភាពជាអ្នកមើលខុសត្រូវលើធនធាន, ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ |

បេសកកម្មពហុគុណ
ម៉ូឌុលការដាំក្រុមជំនុំដែលមានសុខភាពល្អ
ព័ន្ធកិច្ចបណ្តាញពហុគុណ
ក្រុមជំនុំកាន់តែច្រើន / ក្រុមជំនុំកាន់តែរឹងមាំ
**រក្សាសិទ្ធិ © ២០១៥**

មេរៀនហ្វឹកហ្វឺនអ្នកដាំក្រុមជំនុំនេះ គឺជាការរួមបញ្ចូលគ្នានៃវគ្គសិក្សាអាល់ប្រ៊ីឌ អូមេហ្គា និងមេរៀនការដាំក្រុមជំនុំដែលមានសុខភាពល្អរបស់ព័ន្ធកិច្ចបណ្តាញពហុគុណ (MNM)។

MNM បានទទួលការអនុញ្ញាតពីមជ្ឈមណ្ឌលហ្វឹកហ្វឺនអ្នកដាំក្រុមជំនុំ និងពីព័ន្ធកិច្ច Wolrd Ministires ដើម្បីបោះពុម្ពមេរៀននេះឲ្យក្រុមជំនុំប្រើ។

លោកអ្នក**ត្រូវបានអនុញ្ញាត និងលើកទឹកចិត្តឲ្យបោះពុម្ព និងចែកចាយមេរៀននេះ** តាមទម្រង់ណាមួយដែល: (១) ឲ្យតម្លៃប្រភពដើម (២) បញ្ជាក់ប្រាប់ ប្រសិនបើមានការកែសម្រួល (៣) មិនត្រូវយកថ្លៃហួសពីការចំណាយបោះពុម្ព និង (៤) មិនត្រូវថតចម្លង លើសពី ១,០០០ ច្បាប់។

វគ្គអូមេហ្គា:
ការហ្វឹកហ្វឺនអ្នកដាំក្រុមជំនុំ

រក្សាសិទ្ធិ © 2000, 2006 United World Mission.
មេរៀននេះរក្សាសិទ្ធិដើមដោយ The Alliance for Saturation Church Planting ហើយបានរៀបចំឡើងដោយភាពជាដៃគូសហការជាមួយ Peter Deyneka Russian Ministries, Project 250។

ប្រសិនបើលោកអ្នកចង់ដាក់មេរៀននេះនៅលើអ៊ិនធើណេត ឬប្រសិនបើលោកអ្នកមានបំណងចង់ប្រើខុសពីអ្វីដែលបានរៀបរាប់ខាងលើ សូមទំនាក់ទំនង United World Mission, ATTN: Jay Weaver/Omega, 9401-B Southern Pine Blvd., Charlotte, NC 28273-5596, ឬ omega_course@alliancescp.org។

ការបកប្រែ និងការផ្លាស់ប្តូរស្របតាមបរិបទរបស់លោកអ្នក ក៏ត្រូវបានលើកទឹកចិត្តឲ្យធ្វើផងដែរ។

យើងខ្ញុំសូមអរគុណដល់លោកបណ្ឌិត Jerry Wofford និងលោកបណ្ឌិត Jeff Hale សម្រាប់ការរួមចំណែកដ៏មានតម្លៃរបស់ពួកលោក ក្នុងការរៀបចំមេរៀននេះ។
Gary Teja and John Wagenveld បណ្ណាធិការមេរៀនបេសកកម្មពហុគុណ
**www.multiplicationnetwork.org**

| | គម្រូហ្វឹកហ្វឺនសម្រាប់ម៉ូឌុល ៤ រយៈពេលមួយថ្ងៃ | |
|---|---|---|
| | សេចក្តីផ្តើមអំពីម៉ូឌុល ៤ | ៨:០០ |
| | ការចាប់ផ្តើមជាមួយព្រះជាម្ចាស់:<br>គ្រឹះខាងយុទ្ធសាស្ត្រសម្រាប់<br>ក្រុមជំនុំដែលមានសុខភាពល្អ | ៨:១៥ |
| | ការធ្វើរបាយការណ៍ | ៨:៣០ |
| ម៉ោង<br>ទីមួយ | ការប្រោសឲ្យបានសុចរិតដោយសារជំនឿ | ៩:០០ |

| | | |
|---|---|---|
| | សម្រាក | ១០:០០ |
| ម៉ោង ទីពីរ | គោលការណ៍នៅក្នុងព្រះគម្ពីរអំពីការដឹកនាំ | ១០:១៥ |
| ម៉ោង ទីបី | ការផ្សាយដំណឹងល្អ និងការដាំក្រុមជំនុំ | ១១:១៥ |
| | អាហារថ្ងៃត្រង់ | ១២:១៥ |
| ម៉ោង ទីបួន | ការចាប់ផ្តើមក្រុមតូច | ១:១៥ |
| ម៉ោង ទីប្រាំ | ការផ្សាយដំណឹងល្អ និងការបំពេញសេចក្តីត្រូវការរបស់សហគមន៍ | ២:១៥ |
| | សម្រាក | ៣:១៥ |
| ម៉ោង ទីប្រាំមួយ | វិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសានុមាន ៣: ការបកស្រាយព្រះបន្ទូលរបស់ព្រះ | ៣:៣០ |
| | ការបញ្ចប់ | ៤:៣០ |
| | បិទបញ្ចប់ថ្ងៃនោះ | ៤:៤៥ |

# ការចែកចាយដំណឹងល្អ
# ម៉ូឌុល ៤

កម្មវត្ថុមេរៀន:

- សិក្ខាកាមនឹងអាចកំណត់អត្តសញ្ញាណហេតុផលយុទ្ធសាស្ត្របួនសម្រាប់ការដាំក្រុមជំនុំដកស្រង់ចេញពីកណ្ឌគម្ពីរកិច្ចការ។
- សិក្ខាកាមនឹងឲ្យនិយមន័យគោលគំនិតខាងទេវសាស្ត្រអំពីការប្រោសឲ្យបានសុចរិតតាមពាក្យរបស់ពួកគេ និងរៀនរបៀបដឹកនាំការសិក្សាព្រះគម្ពីរដើម្បីពន្យល់គោលគំនិតនេះប្រាប់អ្នកដទៃទៀត។
- សិក្ខាកាមនឹងប្រៀបធៀបការដឹកនាំបែបលោកិយ និងការដឹកនាំបែបគ្រិស្តបរិស័ទ អនុវត្តតួនាទីទាំងប្រាំរបស់ការដឹកនាំនៅក្នុងសញ្ញាថ្មីមកក្នុងវគ្គនៃការដាំក្រុមជំនុំ ហើយពិភាក្សាគ្នាអំពីភាពស័ក្តិសមរបស់ការដឹកនាំបែបបង្គាប់បញ្ជា និងបែបសម្របសម្រួលនៅក្នុងដំណើរការនៃការដាំក្រុមជំនុំ។
- សិក្ខាកាមនឹងរៀន ហើយពិភាក្សាគ្នាទាក់ទងនឹងគោលការណ៍ទាំង ៥ អំពីការផ្សាយដំណឹងល្អសម្រាប់អ្នកដាំក្រុមជំនុំ។
- សិក្ខាកាមនឹងបង្កើតផែនការលម្អិតសម្រាប់ដឹកនាំការជួបប្រជុំក្រុមតូច។
- សិក្ខាកាមនឹងរៀន ហើយបង្កើតសកម្មភាពពាក់ព័ន្ធនឹងទំនាក់ទំនងទាំង ៣ ប្រភេទរបស់ការផ្សាយដំណឹងល្អ និងការបម្រើ។
- សិក្ខាកាមនឹងរៀន ហើយអនុវត្តគោលគំនិតនៃដំណាក់កាលបកស្រាយរបស់ដំណើរការសិក្សាព្រះគម្ពីរបែបវិសេសានុមាន។
- នៅក្នុងផែនការសកម្មភាពសម្រាប់ម៉ូឌុល ៥ ដោយសង់លើកិច្ចការមុន អ្នកដាំក្រុមជំនុំម្នាក់ៗនឹងបង្កើតផែនការមេសម្រាប់ការដាំក្រុមជំនុំ។ ដោយប្រើទម្រង់ដែលបានផ្ដល់ឲ្យ អ្នកដាំក្រុមជំនុំម្នាក់ៗនឹងកំណត់ឲ្យជាក់លាក់ការស្រាវជ្រាវដែលពាក់ព័ន្ធ និមិត្ត បេសកកម្ម គុណតម្លៃស្នូល និងយុទ្ធសាស្ត្រដែលនឹងដឹកនាំការខិតខំប្រឹងប្រែងដាំក្រុមជំនុំរបស់គេ។ អ្នកដាំក្រុមជំនុំម្នាក់ៗត្រូវមានលិខិតឯកភាពពីក្រុមជំនុំដែលឧបត្ថម្ភ និងពីគ្រូគង្វាលរបស់ខ្លួន (បញ្ជាក់ដោយហត្ថលេខារបស់គ្រូគង្វាល) ដែលបង្ហាញប្រាប់ពីការឯកភាពចំពោះផែនការមេសម្រាប់ការដាំក្រុមជំនុំនោះ។

សេចក្ដីផ្ដើមអំពីម៉ូឌុល ៤

ការណែនាំសម្រាប់អ្នកសម្របសម្រួល (២ នាទី)

- ស្វាគមន៍សិក្ខាកាមដោយភាពកក់ក្ដៅ រាក់ទាក់ និងភាពសាទរ។
- នាំមុខសិក្ខាកាមអធិស្ឋានខ្លីជាមួយគ្នា ថ្វាយថ្ងៃនោះសម្រាប់ជាសិរីល្អដល់ព្រះ។

សកម្មភាពល្បែងកម្សាន្ត: តើខ្ញុំជានរណា**?** (១៣ នាទី)

ចូរសរសេរឈ្មោះតួអង្គល្បីៗ និង / ឬតួអង្គនៅក្នុងព្រះគម្ពីរលើបំណែកក្រដាសតូចៗ។ ចូរបិតបំណែកក្រដាសទាំងនោះនៅលើខ្នងមនុស្សគ្រប់គ្នា ដូច្នេះគេមិនអាចមើលបំណែកក្រដាសរបស់ខ្លួនឯងបានទេ។ គេដើរជុំវិញបន្ទប់ សួរសំណួរម្ដងមួយអំពីគេជានរណា រហូតដល់គេទាយដឹងថា គេគឺជានរណា។

នៅពេលដែលបញ្ចប់សកម្មភាពនេះហើយ ចូរឲ្យគ្រប់គ្នាឈរជារង្វង់មូល ហើយប្រាប់ក្រុមថា គេតំណាងឲ្យតួអង្គមួយណានៅក្នុងព្រះគម្ពីរ។ ចូរឲ្យម្នាក់ៗចែកចាយការមួយអំពីតួអង្គក្នុងព្រះគម្ពីររបស់គេដែលគេគិតថាសំខាន់ចំពោះអ្នកដាំក្រុមជំនុំ ឬការដាំក្រុមជំនុំ។ នៅពេលដែលគ្រប់គ្នាចែកចាយរួចហើយ ចូរឲ្យក្រុមត្រឡប់ទៅកន្លែងអង្គុយរបស់ពួកគេវិញសម្រាប់ការចាប់ផ្ដើមជាមួយព្រះ។

## ចាប់ផ្ដើមជាមួយព្រះ
## គ្រឹះខាងយុទ្ធសាស្ត្រសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ (១៥ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរបែងចែកបទគម្ពីរសម្រាប់ហេតុផលខាងទេវសាស្ត្រនីមួយៗឲ្យទៅសិក្ខាកាមផ្សេងៗគ្នា។ ចូរសុំពួកគេអានបទគម្ពីរឮៗឲ្យក្រុមស្ដាប់។ ចូរដឹកនាំក្រុមរកឲ្យឃើញគោលការណ៍បេសកកម្មនីមួយៗចេញពីបទគម្ពីរ ហើយបំពេញឲ្យត្រូវតាមកន្លែងនៅក្នុងសៀវភៅលំហាត់របស់ពួកគេ។

ចូរសួរថា: «តើនរណាអាចប្រាប់យើងបានពីនិយមន័យ«យុទ្ធសាស្ត្រ»ដែលយើងបានរៀននៅក្នុងម៉ូឌុល៣?»។

និយមន័យ: យុទ្ធសាស្ត្រគឺជាបញ្ជីសកម្មភាពជាក់លាក់ដែលលោកអ្នកនឹងធ្វើដើម្បីសម្រេចនិមិត្ត និងបេសកកម្មរបស់លោកអ្នក ខណៈពេលដែលកំពុងរស់នៅតាមគុណតម្លៃស្នូលរបស់លោកអ្នក។

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរនិយាយថា: «យើងក៏អាចគិតបានដែរថា យុទ្ធសាស្ត្រគឺជាជំហានអនុវត្តជាក់ស្ដែងដែលយើងអាចចាត់ឡើង ដើម្បីចែកចាយ និងរស់នៅតាមដំណឹងល្អ នៅពេលដែលយើងដាំក្រុមជំនុំ»។
ចូរដឹកនាំសិក្ខាកាមធ្វើសកម្មភាពខាងក្រោមនៅក្នុងសៀវភៅលំហាត់របស់ពួកគេ។

ហេតុផលយុទ្ធសាស្ត្រទូទៅសម្រាប់ការដាំក្រុមជំនុំ
ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរសុំសិក្ខាកាមឲ្យបំពេញនៅក្នុងបញ្ជី ហើយគូសនៅក្បែរហេតុផលដែលត្រូវនឹងបរិបទរបស់ពួកគេ:

- ☐ ចំនួនប្រជាជនកំពុងកើនឡើងយ៉ាងឆាប់រហ័ស។
- ☐ ក្រុមជំនុំថ្មីឈោងចាប់មនុស្សបានច្រើនជាងក្រុមជំនុំដែលមានរួចហើយ។
- ☐ ក្រុមជំនុំដែលមានរួចហើយហាក់បីដូចជានៅទ្រឹង។
- ☐ ក្រុមជំនុំថ្មីជួយជំរុញក្រុមជំនុំដែលមានរួចហើយ។
- ☐ ក្រុមជំនុំនៅជិតកន្លែងដែលមនុស្សបាត់បង់រស់នៅ។
- ☐ ក្រុមជំនុំថ្មីមានលក្ខណៈបត់បែនខ្លាំងជាង។
- ☐ ក្រុមជំនុំមួយមិនអាចឈោងចាប់មនុស្សគ្រប់គ្នាបានទេ។
- ☐ ក្រុមជំនុំថ្មីអភិវឌ្ឍអ្នកដឹកនាំលឿន។
- ☐ ភាពនៅជិតជួយដល់ការបង្កើតសិស្ស។

សកម្មភាពជាក់លាក់ – និមិត្ត –បេសកកម្ម – រស់នៅតាម

រហូតមកដល់ពេលនេះ តើលោកអ្នកមិនគិតដល់ហេតុផលមួយណាខ្លះក្នុងចំណោមហេតុផលសម្រាប់ការដាំក្រុមជំនុំ? តើហេតុផលមួយណាខ្លះនឹងលើកទឹកចិត្តមនុស្សដែលលោកអ្នកនឹងធ្វើការជាមួយដើម្បីដាំក្រុមជំនុំ?

____________________________________________________________________________________
____________________________________________________________________________________
____________________________________________________________________________________

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរនិយាយថា: «ចូរពិចារណាជាមួយគ្នាហេតុផលមួយចំនួនដែលនាំឲ្យក្រុមជំនុំសញ្ញាថ្មីមួយចំនួនបានចាប់ផ្តើមឡើង»។

ហេតុផលដែលនាំឲ្យក្រុមជំនុំសញ្ញាថ្មីមួយចំនួនបានចាប់ផ្តើមឡើង:
ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរបែងចែកបទគម្ពីរសម្រាប់ហេតុផលនីមួយៗឲ្យទៅសិក្ខាកាមផ្សេងៗគ្នា។ ចូរសុំពួកគេអានបទគម្ពីរឮៗឲ្យក្រុមស្តាប់។ ចូរដឹកនាំក្រុមរកឲ្យឃើញហេតុផលនីមួយៗសម្រាប់ការដាំក្រុមជំនុំចេញពីបទគម្ពីរ ហើយបំពេញឲ្យត្រូវតាមកន្លែងនៅក្នុងសៀវភៅលំហាត់របស់ពួកគេ។

ចូរអាន: កិច្ចការ ៨:១-៨, ១២
ហេតុផលយុទ្ធសាស្ត្រទី ១: ការឆ្លើយតបចំពោះ<u>ការបៀតបៀន</u>។ ការដាំក្រុមជំនុំថ្មីៗក្រៅក្រុងយេរូសាឡិមដែលត្រូវបានកត់ត្រាមុនគេគឺជាលទ្ធផលកើតចេញពីការបៀតបៀន។ ចូរពិភាក្សាអំពីរបៀបដែលការដាំក្រុមជំនុំអាចជាការឆ្លើយតបបែបយុទ្ធសាស្ត្រ/អនុវត្តជាក់ស្តែងចំពោះការបៀតបៀន។ ចូរសួរសិក្ខាកាមថាតើពួកគេអាចឲ្យឧទាហរណ៍អំពីក្រុមជំនុំដែលត្រូវបានដាំជាការឆ្លើយតបចំពោះការបៀតបៀន ចេញពីបទពិសោធន៍របស់ពួកគេ ឬចេញពីចំណេះដឹងរបស់ពួកគេអំពីបទពិសោធន៍របស់អ្នកដទៃទៀតបានដែរឬយ៉ាងណា។

ចូរអាន: កិច្ចការ ១០:១-២៤, ៣៦-៤៨
ហេតុផលយុទ្ធសាស្ត្រទី ៤: ការឆ្លើយតបចំពោះ<u>ការដឹកនាំរបស់ព្រះ</u> ។ ព្រះជាម្ចាស់បានប្រទានការដឹកនាំជាក់លាក់ដល់លោកកូនេលាស និងលោកពេត្រុស។ ក្រុមជំនុំនៅក្រុងសេសារាត្រូវបានដាំ ដោយព្រោះតែពួកគេស្តាប់បង្គាប់តាមការណែនាំដ៏ជាក់លាក់របស់ព្រះ។ ចូរពិភាក្សាអំពីរបៀបដែលព្រះជាម្ចាស់បានបើកសម្តែងអង្គទ្រង់ឲ្យលោកកូនេលាស និងលោកពេត្រុសបានឃើញ។ តើពួកគេបានដឹងយ៉ាងដូចម្តេចថា ព្រះជាម្ចាស់កំពុងមានបន្ទូលមកកាន់ពួកគេ? តើយើងដឹងយ៉ាងដូចម្តេច នៅពេលដែលព្រះជាម្ចាស់ប្រទានការដឹកនាំជាក់លាក់ដល់យើង? ចូរសួរសិក្ខាកាមថាតើពួកគេអាចឲ្យឧទាហរណ៍អំពីក្រុមជំនុំដែលត្រូវបានដាំជាការឆ្លើយតបចំពោះការណែនាំជាក់លាក់មកពីព្រះ តាមបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ ឬចេញពីចំណេះដឹងរបស់ពួកគេអំពីបទពិសោធន៍របស់អ្នកដទៃទៀតបានដែរឬយ៉ាងណា។

ហេតុផលយុទ្ធសាស្ត្រទី ៣: ការឆ្លើយតបចំពោះ<u>ការអញ្ជើញ</u>។ លោកពេត្រុសបានឆ្លើយតបចំពោះការអញ្ជើញពីលោកកូនេលាស។ ដោយព្រោះតែសកម្មភាពរបស់ព្រះដែលលោកពេត្រុសបានឃើញនៅក្នុងផ្ទះរបស់លោកកូនេលាស លោកពេត្រុសអាចសង្កេតដឹងថា ការអញ្ជើញនោះក៏ជាមួយផ្នែកនៃសកម្មភាពរបស់ព្រះដែរ ដូច្នេះលោកពេត្រុសបានផ្លាស់ប្តូរកាលវិភាគរបស់លោកស្របទៅតាមនោះ។ ចូរសួរសិក្ខាកាមថាតើពួកគេអាចឲ្យឧទាហរណ៍អំពីក្រុមជំនុំដែលត្រូវបានដាំជាការឆ្លើយតបចំពោះការអញ្ជើញឲ្យទៅទីតាំងជាក់
ការបៀតបៀន ការដឹកនាំរបស់ព្រះ ការអញ្ជើញ
លាក់មួយតាមបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ ឬចេញពីចំណេះដឹងរបស់ពួកគេអំពីបទពិសោធន៍របស់អ្នកដទៃទៀតបានដែរឬយ៉ាងណា។

ចូរអាន: កិច្ចការ ១៦:៩-១៥
ហេតុផលយុទ្ធសាស្ត្រទី ៤: <u>ទម្លាប់ដ៏ស្មោះត្រង់</u>ក្នុងការចែកចាយដំណឹងល្អ។ ក្រុមជំនុំនៅក្រុងភីលីពត្រូវបានដាំ ដោយព្រោះលោកប៉ុលមានទម្លាប់ស្មោះត្រង់នៅក្នុងការចែកចាយដំណឹងល្អនៅគ្រប់ទីកន្លែងដែលលោកបានធ្វើដំណើរទៅ។ លោកប៉ុលកំពុងធ្វើដំណើរទៅស្រុកម៉ាសេដូន ហើយបានឆ្លងកាត់ក្រុងភីលីព។ ដោយព្រោះតែលោកប៉ុលមានទម្លាប់ដ៏ស្មោះត្រង់នៅក្នុងការចែកចាយដំណឹងល្អ នាងលីឌាបានក្លាយទៅជាអ្នកជឿ ហើយក្រុមជំនុំត្រូវបានចាប់ផ្តើមឡើងដែលឈរយ៉ាងស្មោះត្រង់ជាមួយលោកប៉ុល និងធ្វើជាព្រះពរដល់ក្រុមជំនុំដទៃទៀត។ ចូរសួរសិក្ខាកាមថាតើពួកគេអាចឲ្យឧទាហរណ៍អំពីក្រុមជំនុំដែលត្រូវបានដាំដោយព្រោះតែទម្លាប់ដ៏ស្មោះត្រង់នៅក្នុងការចែកចាយដំណឹងល្អ តាមបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ

ឬចេញពីចំណេះដឹងរបស់ពួកគេអំពីបទពិសោធន៍របស់អ្នកដទៃទៀតបានដែរឬយ៉ាងណា។

ការរាយការណ៍ (៣០ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួលៈ

- ដោយប្រើទម្រង់របាយការណ៍ខាងក្រោម ចូរដឹកនាំសិក្ខាកាមចែកចាយសកម្មភាពដាំក្រុមជំនុំរបស់ពួកគេចាប់តាំងពីបញ្ចប់ម៉ូឌុល ២ មក។
- ចូរអបអរនឹងជ័យជម្នះ ហើយលើកទឹកចិត្តអ្នកដែលបាក់ទឹកចិត្ត។ តាមពេលវេលាដែលមានលោកអ្នកប្រហែលជាចង់ចំណាយពេលអធិស្ឋានឲ្យគ្នាទៅវិញទៅមកនៅក្នុងក្រុមតូចអំពីបទពិសោធន៍ដាំក្រុមជំនុំទាំងនេះ។
- ចូរឆ្លើយសំណួរណាមួយអំពីដំណើរការរាយការណ៍។

ទម្លាប់ដ៏ស្មោះត្រង់

# របាយការណ៍ដាំក្រុមជំនុំកខគ

របាយការណ៍ប្រចាំខែ

## ព័ត៌មានទូទៅ

| | | | | |
|---|---|---|---|---|
| របាយការណ៍ខែ | | បានជួបប្រជុំជាមួយគ្រូឧបជ្ឈា | បាទ/ចាស | ទេ |

| | |
|---|---|
| ឈ្មោះអ្នកដាំក្រុមជំនុំ | |
| តំបន់របស់អ្នកដាំក្រុមជំនុំ | |
| អ្នកសម្របសម្រួលតំបន់ | |

| បុគ្គល | គោលដៅប្រចាំខែ | លទ្ធផលប្រចាំខែ |
|---|---|---|
| អ្នកថ្មីដែលត្រូវទាក់ទង<br>អ្នកដែលត្រូវបានទាក់ទងនៅក្នុងបរិបទដាំក្រុមជំនុំ ដើម្បីប្រាប់ដំណឹងល្អ | | |
| ការប្រែចិត្តថ្មី<br>អ្នកដើរតាមព្រះយេស៊ូ | | |
| អ្នកថ្មីដែលបានទទួលបុណ្យជ្រមុជទឹក<br>អ្នកដែលបានទទួលពិធីបុណ្យជ្រមុជទឹក | | |
| អ្នកដឹកនាំថ្មីដែលកំពុងទទួលការហ្វឹកហ្វឺន<br>អ្នកដែលអ្នកដាំក្រុមជំនុំកំពុងហ្វឹកហ្វឺនឲ្យធ្វើជាអ្នកដឹកនាំ | | |

| ក្រុមតូចៈ ជាអប្បបរិមា សិស្សថ្មីពីរនាក់ និងអ្នកដឹកនាំម្នាក់ | គោលដៅប្រចាំខែ | លទ្ធផលប្រចាំខែ |
|---|---|---|
| ក្រុមតូចថ្មី<br>ក្រុមដែលបានចាប់ផ្ដើមខែនេះ | | |
| អ្នកចូលរួមថ្មីនៅក្នុងក្រុមតូច<br>មនុស្សថ្មីដែលចូលរួមក្រុមតូចនៅខែនេះ | | |
| អ្នកដឹកនាំថ្មីដែលមានមួយក្រុម<br>អ្នកដឹកនាំថ្មីដែលមានមួយក្រុមនៅក្រោមការត្រួតពិនិត្យមើលរបស់អ្នកដាំពូកជំនុំ | | |

## សំណូមពរអធិស្ឋាន (តម្រូវឲ្យសរសេរយ៉ាងតិចពេញមួយប្រឡោះនេះ)

## ទីបន្ទាល់

ព័ន្ធកិច្ចបណ្ដាញពហុគុណ | កខគ របស់អ្នកដាំក្រុមជំនុំ

# ម៉ោងទី ១
# ការប្រោសឲ្យបានសុចរិតដោយសារជំនឿ: គ្រឹះនៃទំនាក់ទំនងរបស់យើងជាមួយព្រះ (៦០ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួលៈ ដោយប្រើមេរៀនខាងក្រោម ចូរដឹកនាំក្រុមនៅក្នុងការសិក្សាព្រះគម្ពីរបែបវិសេសានុមានអំពីប្រធានបទការប្រោសឲ្យបានសុចរិត។ ចូរឲ្យសិក្ខាកាមបំពេញគ្រោងខាងក្រោមនៅក្នុងសៀវភៅលំហាត់របស់ពួកគេ ហើយបង្កើតនិយមន័យការប្រោសឲ្យបានសុចរិតតាមពាក្យរបស់ពួកគេ។

សេចក្ដីផ្ដើម (១០ នាទី)
តើយើងអាចស្គាល់ព្រះជាម្ចាស់នៅក្នុងទំនាក់ទំនងដ៏ជិតស្និទ្ធ និងប្រកបដោយសេចក្ដីស្រលាញ់បានយ៉ាងដូចម្ដេច?
តើព្រះជាម្ចាស់ពិតជាទទួលយកយើងដែរឬទេ?
តើការទទួលយកយើងនៅចំពោះព្រះចេញមកពីកន្លែងណា?
តើយើងអាចរស់នៅក្នុងជីវិតដែលសព្វព្រះហឫទ័យដល់ព្រះអង្គបានយ៉ាងដូចម្ដេច?
តើមានអ្វីកើតឡើង នៅពេលដែលយើងធ្វើបាប?

លោក មីលលត អ៊ែរិកស៊ិន ជាទេវវិទូគ្រិស្តបរិស័ទម្នាក់ បានសរសេរថា:
*ផ្នែកមួយចំនួននៃគោលលទ្ធិអំពីសេចក្ដីសង្គ្រោះពាក់ព័ន្ធនឹងការដែលមនុស្សឈរខាងព្រះជាម្ចាស់។ ឋានៈតាមផ្លូវច្បាប់របស់បុគ្គលត្រូវបានផ្លាស់ប្ដូរពីអ្នកមានទោសទៅជាអ្នកគ្មានទោស។ នេះគឺជាការដែលមនុស្សម្នាក់ត្រូវបានប្រកាសថាសុចរិតនៅចំពោះព្រះនេត្ររបស់ព្រះ ត្រូវបានចាត់ទុកជាអ្នកដែលបានបំពេញតាមគ្រប់ទាំងលក្ខខណ្ឌរបស់ព្រះ។ ពាក្យខាងទេវសាស្ត្រនៅត្រង់នេះ គឺជាការប្រោសឲ្យបានសុចរិត...ការប្រោសឲ្យបានសុចរិតគឺជាសកម្មភាពសម្រេចក្ដី ឬការប្រកាសរបស់ព្រះ ដូចជាសកម្មភាពសម្រេចក្ដីរបស់ចៅក្រម ដែលឲ្យចុងចោទរួចខ្លួន...ការប្រោសឲ្យបានសុចរិត ផ្សាភ្ជាប់យ៉ាងជិតស្និទ្ធជាមួយការរួមជាមួយនឹងព្រះគ្រិស្ត។*

ការសិក្សាព្រះគម្ពីរ (១០ នាទី)

I. ការប្រោសឲ្យបានសុចរិត មិនមែន
ក. ដោយសារ<u>ការប្រព្រឹត្ត</u>
ខ. ការលើកលែងទោសដែលព្រះជាម្ចាស់<u>ព្រងើយកន្តើយ</u>ចំពោះអំពើបាបរបស់យើង
II. ការប្រោសឲ្យបានសុចរិតគឺជា
ក. <u>សេចក្ដីសុចរិត</u>របស់ព្រះ រ៉ូម ៣:២១-២៤
ខ. <u>ការដោះដូរ</u>ដ៏ធំ: ២ កូរិនថូស ៥:២១ អេសាយ ៦១:១០ រ៉ូម ៤:៣-៥, ៨:១ អេភេសូរ ៤:២២-២៤
III. បញ្ហាសំខាន់ៗអំពីការប្រោសឲ្យបានសុចរិតដោយសារជំនឿ
ក. តើយើងអាចធ្វើឲ្យខ្លួនឯងបានសុចរិតដែរឬទេ?
ការប្រព្រឹត្ត – ព្រងើយកន្តើយ – សេចក្ដីសុចរិត – ការដោះដូរ
ខ. តើយើងអាចយកសិរីរុងរឿងសម្រាប់អ្វីដែល<u>ព្រះជាម្ចាស់</u>បានធ្វើសម្រាប់យើងបានដែរឬទេ?

ឧទាហរណ៍ (៣០ នាទី)
ឧបមាថា មានបុរសម្នាក់បានប្រព្រឹត្តបទឧក្រិដ្ឋដ៏ធ្ងន់ធ្ងរ ហើយកំពុងរង់ចាំការកាត់ទោសប្រហារជីវិត។ នៅពេលដែលគាត់កំពុងរង់ចាំ មិត្តភក្ដិម្នាក់របស់គាត់បានទៅជួបចៅក្រម ហើយសុំឲ្យលើកលែងទោសឲ្យបុរសនោះ។ ចៅក្រមឆ្លើយថា: «យើងនឹងដោះលែងបុរសនោះ ប្រសិនបើឯងឲ្យកូនប្រុសឯងមកស្លាប់ជំនួសគាត់»។ មិត្តភក្ដិនោះក៏ឆ្លើយឡើងថា: «នេះគួរឲ្យអស់សំណើចណាស់ តើខ្ញុំអាចធ្វើបែបនេះបានយ៉ាងដូចម្ដេច?» ប៉ុន្តែចៅក្រមនិយាយថា: «នេះគឺជាវិធីតែមួយគត់ដែលយើងអាចដោះលែងបុរសនោះឲ្យមានសេរីភាពបាន»។ ក្រោយពីមានការឈឺចាប់យ៉ាងខ្លាំង ឪពុកនោះសម្រេចចិត្តថា គាត់នឹងលះបង់កូនប្រុសរបស់គាត់ដើម្បីមិត្តភក្ដិនោះ...ដោយដឹងថា នោះគឺជាវិធីតែមួយគត់។ ដោយស្ដាប់បង្គាប់ កូនប្រុសនោះក៏ទៅជួបចៅក្រម ហើយព្រមស្លាប់ជំនួសមិត្តភក្ដិឪពុករបស់គាត់។ ថ្ងៃបន្ទាប់ ចៅក្រមកាត់ទោសកូនប្រុសនោះ ហើយដោះលែងបុរសនោះឲ្យមានសេរីភាព។ ភ្លាមៗក្រោយហេតុការណ៍នោះ ឪពុកបានលួចស្ដាប់ឮការសន្ទនារវាងអ្នកទោសដែលបានដោះលែងឲ្យមានសេរីភាព និងមិត្តភក្ដិម្នាក់។ នៅពេល

ដែលត្រូវបានសួរថា: «តើឯងត្រូវបានដោះលែងឲ្យរួចផុតពីទោសប្រហារជីវិតយ៉ាងដូចម្ដេច?» បុរសដែលត្រូវបានដោះលែងនោះឆ្លើយថា: «ពេលដែលខ្ញុំនៅក្នុងគុក ខ្ញុំបានធ្វើឲ្យខ្លួនឯងស្អាត ប្រកាន់អាកប្បកិរិយាត្រឹមត្រូវ និងបានធ្វើអ្វីដែលអ្នកយាមប្រាប់ ដូច្នេះ ពួកគេបានដោះលែងខ្ញុំ ដោយព្រោះតែការប្រព្រឹត្តិល្អរបស់ខ្ញុំ»។

ការពិភាក្សា:
តើលោកអ្នកគិតថា ឪពុកឆ្លើយតបចំពោះអ្វីដែលមិត្តភក្តិរបស់គាត់បាននិយាយយ៉ោងដូចម្ដេច?

តើបុរសដែលត្រូវបានដោះលែងនោះអាចគិតបានយ៉ាងដូចម្ដេចថា ការប្រព្រឹត្តិរបស់គាត់មានការពាក់ព័ន្ធនឹងការដោះលែងគាត់ ក្រោយពីកូនប្រុសនោះបានលះបង់ជីវិតសម្រាប់គាត់?

តើយើងត្រូវតែទុកចិត្តព្រះជាម្ចាស់ទាំងស្រុង និងតែមួយគត់ដែរឬទេ?

តើមានន័យយ៉ាងដូចម្ដេច នៅពេលដែលយើងពណ៌នាការប្រោសឲ្យបានសុចរិតដោយសរជំនឿថាជា«សេចក្ដីសុចរិតអកម្ម»?

នៅក្នុងការដើររាល់ថ្ងៃរបស់យើងជាមួយព្រះអម្ចាស់ ហេតុអ្វីបានជាយើងដែលបានចាប់ផ្ដើមនៅក្នុងព្រះគុណពិបាកខ្លាំងម្ល៉េះនៅក្នុងការបន្តនៅក្នុងព្រះគុណ ដោយទុកចិត្តលើកិច្ចការដែលបានចប់សព្វគ្រប់របស់ព្រះយេស៊ូគ្រីស្តនៅលើឈើឆ្កាង?

តើការប្រោសឲ្យបានសុចរិតដោយសារជំនឿ មានឥទ្ធិពលយ៉ាងដូចម្ដេចលើរបៀបដែលយើងមានទំនាក់ទំនងជាមួយព្រះ និងរបៀបដែលលោកអ្នកគិតថា ព្រះអង្គមានទំនាក់ទំនងជាមួយលោកអ្នក?

ការផ្ទុះបញ្ចាំង: (១០ នាទី)
នៅក្នុងប្រឡោះដែលបានផ្ដល់ឲ្យ ចូរសរសេរនិយមន័យរបស់លោកអ្នកសម្រាប់ «ការប្រោសឲ្យបានសុចរិតដោយសារជំនឿ»។

______________________________________________________________

______________________________________________________________

______________________________________________________________

ផែនការសកម្មភាពសម្រាប់ម៉ូឌុល ៥

មុនពេលដែលត្រឡប់មករៀនម៉ូឌុល ៥ ចូរដឹកនាំមនុស្សម្នាក់ទៀត ឬក្រុមតូចនៅក្នុងការសិក្សាព្រះគម្ពីរបែបវិសេសានុមានអំពីការប្រោសឲ្យបានសុចរិតដោយសារជំនឿ បន្ទាប់មកចូរឲ្យអ្នកនោះ ឬក្រុមតូចនោះសរសេរនិយមន័យរបស់ពួកគេសម្រាប់ការប្រោសឲ្យបានសុចរិតដោយសារជំនឿ។ ចូរនាំយកអ្វីដែលពួកគេបានសរសេរមកកាន់ការហ្វឹកហ្វឺនលើកក្រោយទៀត។

សម្រាក (១៥ នាទី)

# ម៉ោងទី ២
# គោលការណ៍នៅក្នុងព្រះគម្ពីរអំពីការដឹកនាំ (៦០ នាទី)

## និយមន័យការដឹកនាំ (១០ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរនិយាយថ១០: «ចូរចំណាយពេលមួយនាទីដើម្បីឲ្យនិយមន័យពាក្យ «ការដឹកនាំ»ដោយប្រើពាក្យតិចបំផុតតាមដែលអាចធ្វើបាននៅក្នុងប្រឡោះដែលបានផ្ដល់ឲ្យនៅក្នុងសៀវភៅលំហាត់របស់លោកអ្នក»។

និយមន័យរបស់ខ្ញុំសម្រាប់ការដឹកនាំ:

________________________________________

________________________________________

________________________________________

ចូរនិយាយថា: «ចូររកដៃគូ ហើយចែកចាយនិយមន័យរបស់លោកអ្នកអំពីការដឹកនាំប្រាប់គ្នាទៅវិញទៅមក»។

ចូរពិភាក្សាចំណុចខាងក្រោមនៅក្នុងក្រុមធំ។

- «ការដឹកនាំគឺជាឥទ្ធិពល ជាសមត្ថភាពរបស់មនុស្សម្នាក់ដើម្បីមានឥទ្ធិពលលើមនុស្សដទៃទៀត» (សិនឌើរ *ការដឹកនាំខាងវិញ្ញាណ* ទំព័រ ៣១)។
- «ការដឹកនាំគឺជាដំណើរការរស់រវើកដែលក្នុងនោះមនុស្សប្រុស ឬមនុស្សស្រីដែលមានសមត្ថភាពមកពីព្រះមានឥទ្ធិពលលើប្រជារាស្ត្ររបស់ព្រះ ឆ្ពោះទៅរកគោលបំណងរបស់ព្រះ សម្រាប់ក្រុមនោះ» (គ្លីនតុន *ការបង្កើតអ្នកដឹកនាំ* ទំព័រ ១៤ និងទំព័រ ១២៧)។
- ចូរប្រៀបធៀបនិយមន័យរបស់លោកអ្នកអំពីការដឹកនាំជាមួយនឹងនិយមន័យរបស់លោកសិនឌើរ និងលោកគ្លីនតុន។
- និយមន័យតែមួយម៉ាត់សម្រាប់ការដឹកនាំអាចថា ការដឹកនាំគឺជា«ឥទ្ធិពល»។
- តើការឲ្យនិយមន័យការដឹកនាំថាជា«ឥទ្ធិពល»មានការប្រាប់ដោយប្រយោលអ្វីខ្លះ?
- តើនរណាគឺជាអ្នកដឹកនាំនៅក្នុងក្រុមជំនុំ ឬព័ន្ធកិច្ចរបស់លោកអ្នកដែលជាមនុស្សមានឥទ្ធិពល?

## គោលការណ៍អំពីការដឹកនាំនៅក្នុងព្រះគម្ពីរ (៥ នាទី)

ជាញឹកញាប់ អ្នកដឹកនាំបែបលោកិយគិតថា «អ្នកដឹកនាំមិនអាចទុកចិត្តថ្នាក់ក្រោមរបស់ខ្លួនឲ្យធ្វើអ្វីដែលពួកគេគួរតែធ្វើទេ» និងគិតថា «ប្រសិនបើអ្នកទុកចិត្តមនុស្សខ្លាំងពេក ពួកគេនឹងកេងចំណេញលើអ្នក»។ អ្នកដឹកនាំបែបលោកិយប្រហែលជាជឿទៀតថា មនុស្សនឹងធ្វើអ្វីដែលលោកអ្នកចង់ឲ្យពួកគេធ្វើ នៅពេលដែលមានរង្វាន់លើកទឹកចិត្ត ឬគំរាមកំហែងដាក់ទោសប៉ុណ្ណោះ។ ជាលទ្ធផលនៃបុរេគំនិតទាំងនេះ ជាញឹកញាប់ អ្នកដឹកនាំបែបលោកិយមានសិទ្ធិអំណាចដោយផ្អែកលើតួនាទីដែលពួកគេមាន ឬដោយសារអំណាចរបស់បុគ្គលិកលក្ខណៈតែប៉ុណ្ណោះ។ ការដឹកនាំបែបលោកិយអាចកើតឡើងនៅក្នុងលោកិយ និងនៅក្នុងក្រុមជំនុំ។
ឥទ្ធិពល – របស់ព្រះ - ឥទ្ធិពល

| ប្រភពទាំងប្រាំពីររបស់អំណាច |
|---|

នេះជាប្រភពទាំងប្រាំពីររបស់អំណាច។ ប្រភពទាំងអស់នេះ អាចល្អ ឬអាក្រក់ ដោយផ្អែកលើរបៀបដែលប្រភពទាំងនោះត្រូវបានប្រើ។ តើលោកអ្នកស្គាល់ប្រភពមួយណាខ្លះ?

រយៈពេលធ្វើការងារ—ដោយផ្អែកលើពេលវេលា
តួនាទី—ដោយផ្អែកលើមុខងារ
សមត្ថភាព—ដោយផ្អែកលើអំណោយទាន
ការភ័យខ្លាច—ដោយផ្អែកលើការភ័យខ្លាច និងរង្វាន់
ការគោរព—ដោយផ្អែកលើអត្តចរិត និងបុគ្គលិកលក្ខណៈ
ព័ត៌មាន—ដោយផ្អែកលើលទ្ធភាពជួបបាន និងចំណេះដឹង
ទំនាក់ទំនង—ដោយផ្អែកលើមិត្តភាព ឬការផ្សាភ្ជាប់

មកពី «ភាពឆ្នៃប្រឌិត និងការកែឆ្នៃនៅក្នុងការដឹកនាំ»
ថ្នាក់បណ្ឌិតបង្រៀនដោយបណ្ឌិត ឡារី អូសបន។

ការពិភាក្សា: (២៥ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរប្រើមេរៀនខាងក្រោម ដើម្បីដឹកនាំការពិភាក្សាប្រៀបធៀបរវាងការដឹកនាំបែបលោកិយ និងការដឹកនាំបែបគ្រិស្តបរិស័ទ។ ចូរចំណាយពេលអាន និងទាញយកគោលការណ៍ដឹកនាំចេញពីអត្ថបទគម្ពីរដែលបានផ្ដល់ឲ្យ។ នៅក្នុងអំឡុងពេលនៃការពិភាក្សា ចូរឲ្យសិក្ខាកាមបំពេញនៅក្នុងតារាងខាងក្រោម។

ដោយពិចារណាអំពីទំនាក់ទំនងរវាងចៅហ្វាយ និងទាសករនៅក្នុងសម័យរបស់លោកប៉ុល តើអេភេសូរ ៦:៩ ប្រាប់យើងអ្វីខ្លះអំពីការគំរាមកំហែងមនុស្សដែលនៅក្រោមសិទ្ធិអំណាចរបស់យើង?

តើលោកអ្នកធ្លាប់មានអារម្មណ៍រងគ្រោះដោយសារអ្នកដឹកនាំដែលបានប្រកាន់ឥរិយាបថស្របតាមគំនិតខាងលើដែរឬទេ? តើការនោះបានជះឥទ្ធិពលដល់លោកអ្នកយ៉ាងដូចម្ដេច?

____________________________________________
____________________________________________
____________________________________________

ក. សិទ្ធិអំណាចដឹកនាំមកពីព្រះ។
តើខគម្ពីរខាងក្រោមបង្រៀនយើងយ៉ាងដូចម្ដេចអំពីសិទ្ធិអំណាចដែលព្រះជាម្ចាស់ជាអ្នកបង្កើតឡើង?

- រដ្ឋាភិបាលស៊ីវិលមានសិទ្ធិអំណាចស្របច្បាប់ (រ៉ូម ១៣:១-៧, ១ ពេត្រុស ២:១៣-១៧)
- គ្រួសារ (អេភេសូរ ៥:២២-២៥, ៦:១-៤)
- ក្រុមជំនុំ (ហេព្រើរ ១៣:១៧)
- គំរូរបស់ព្រះយេស៊ូ (យ៉ូហាន ៨:២៨-២៩)
- អ្នកដឹកនាំគ្រិស្តបរិស័ទត្រូវបានព្រះជាម្ចាស់ជ្រើសរើស (យ៉ូហាន ១៥:១៦)

ខ. ការបន្ទាបខ្លួនបម្រើគួរតែជាអត្តចរិតរបស់អ្នកដឹកនាំគ្រិស្តបរិស័ទ។
តើខគម្ពីរទាំងនេះប្រាប់អ្វីដល់យើងដែលផ្ទុយពីភាពជាអ្នកបម្រើ? ចម្លើយមួយដែលអាចគឺជាអំនួត។

- ព្រះអម្ចាស់ស្អប់អំនួត (សុភាសិត ៦:១៦-១៧)
- គំរូរបស់ព្រះយេស៊ូ (ភីលីព ២:១-៨ យ៉ូហាន ១៣:១៥)

គ. ការដឹកនាំបែបគ្រិស្តបរិស័ទត្រូវបានអភិវឌ្ឍឡើងតាមរយៈការសិក្សាដោយប្រុងប្រយ័ត្ន និងការអនុវត្តន៍។

- ការយកចិត្តទុកដាក់នៅក្នុងការបណ្តុះសមត្ថភាពបង្រៀនព្រះបន្ទូលរបស់ព្រះយ៉ាងត្រឹមត្រូវ (២ ធីម៉ូថេ ២:១៥)
- ការគ្រប់គ្រងរូបកាយ (រ៉ូម ៦:១៣, ១ កូរិនថូស ៦:២០)
- ភាពខ្ជាប់ខ្ជួននៅក្នុងពេលមានការល្បួងល (យ៉ាកុប ១:១២)

*ការខុសប្លែកគ្នារវាងការដឹកនាំបែបលោកិយ និងការដឹកនាំបែបគ្រិស្តបរិស័ទ*

| អ្នកដឹកនាំលោកិយ | អ្នកដឹកនាំគ្រិស្តបរិស័ទ |
|---|---|
| ទំនុកចិត្តលើខ្លួនឯង | ទំនុកចិត្តលើព្រះ |
| យល់អំពីមនុស្ស | យល់អំពីព្រះ និងមនុស្ស |
| សម្រេចចិត្តតាមខ្លួនឯង | ស្វែងរកបំណងព្រះហឫទ័យរបស់ព្រះ |
| មានមហិច្ឆតា | ដូចជាអ្នកបម្រើ |
| បង្កើតវិធីសាស្ត្រខ្លួនឯង | ស្វែងរក និងធ្វើតាមវិធីសាស្ត្ររបស់ព្រះ |
| ចូលចិត្តបញ្ជាអ្នកដទៃ | រីករាយនឹងស្តាប់បង្គាប់ព្រះ |
| បណ្តាលចិត្តដោយសារការខ្វល់ខ្វាយផ្ទាល់ខ្លួន | បណ្តាលចិត្តដោយសារសេចក្តីស្រឡាញ់ចំពោះព្រះ និងមនុស្ស |
| ឯករាជ្យ | ពឹងផ្អែកលើព្រះ |

ចូរសួរថា៖ «នៅពេលដែលមនុស្សនិយាយអំពី«អ្នកដឹកនាំពីកំណើត» ជាធម្មតា តើពួកគេផ្អែកគំនិតនោះនៅលើលក្ខណៈរបស់«ការដឹកនាំបែបលោកិយ» ឬ«ការដឹកនាំបែបគ្រិស្តបរិស័ទ»»?

ឃ. ព្រះគម្ពីរពណ៌នាអំពីភាពផ្សេងៗគ្នានៃរបៀបដឹកនាំ។

អេភេសូរ ៤:១១-១២ ពណ៌នាអំពីតួនាទីដឹកនាំជាច្រើនដែលមាននៅក្នុងក្រុមជំនុំសញ្ញាថ្មី។ ទោះបីជាខុសពីគ្នាក៏ដោយ តួនាទីនីមួយៗដំណើរការទៅដើម្បី«រៀបចំប្រជារាស្ត្ររបស់ព្រះសម្រាប់កិច្ចការបម្រើ» ឬនិយាយបានម្យ៉ាងទៀតថា ដើម្បីបំពាក់បំប៉នប្រជារាស្ត្ររបស់ព្រះឲ្យបម្រើព្រះអង្គ និងបម្រើគ្នាទៅវិញទៅមក។

*តួនាទីដឹកនាំនៅក្នុងសញ្ញាថ្មី*

| អំណោយទាន | ការខ្វល់ខ្វាយ | តួនាទី |
|---|---|---|
| សាវក | និមិត្ត | អ្នកត្រួសត្រាយផ្លូវ |
| ហោរា | អំពើបាប | ប្រកាសព្រះបន្ទូល |
| អ្នកផ្សាយដំណឹងល្អ | សេចក្តីសង្គ្រោះ | ឈោងចាប់ខាងក្រៅ |
| គ្រូគង្វាល | ថែបំប៉ន | ឈោងចាប់ខាងក្នុង |

| គ្រូបង្រៀន | សេចក្តីពិត | ណែនាំ |
| --- | --- | --- |

ការពិភាក្សានៅក្នុងក្រុមតូច (៥ នាទី)
ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរដាក់បញ្ជីសកម្មភាពនៅក្នុង«វដ្តនៃការដាំក្រុមជំនុំ»ដែលមាននៅក្នុងម៉ូឌុល ១ នៅលើក្តារខៀន ឬផ្ទាំងក្រដាសធំ។ សកម្មភាពទាំងនោះមានអធិស្ឋាន ផ្សាយដំណឹងល្អ បង្កើតសិស្ស ជួបជុំគ្នា អភិវឌ្ឍអ្នកដឹកនាំ ចម្រើនឡើងជាពហុគុណ និងចលនា។ បន្ទាប់មក នៅក្នុងក្រុមតូច (ប្រសិនបើថ្នាក់ធំ) ចូរពិភាក្សាអំពីតួនាទីដឹកនាំនៅក្នុងសញ្ញាថ្មីដែលចាំបាច់សម្រាប់ដំណាក់កាលនីមួយៗរបស់វដ្ត។

*បន្តពិភាក្សាជាក្រុមធំ (៥ នាទី)

ង. តួនាទីចម្បងរបស់អ្នកដឹកនាំក្រុមជំនុំគឺ<u>បំពាក់បំប៉ន</u>។
តើអេភេសូរ ៤:១១-១២ ប្រាប់យើងថា ការទទួលខុសត្រូវចម្បងរបស់អ្នកដឹកនាំក្រុមជំនុំគឺជាអ្វី?

ភាពផ្សេងៗគ្នា - បំពាក់បំប៉ន

*អ្នកដឹកនាំដែលបង្គាប់បញ្ជា និងអ្នកដឹកនាំដែលសម្របសម្រួល*

កំណត់សម្គាល់: ទាំងការដឹកនាំបែបបង្គាប់បញ្ជា ទាំងការដឹកនាំបែបសម្របសម្រួល សុទ្ធតែមានប្រសិទ្ធភាពនៅក្នុងព័ន្ធកិច្ចគ្រិស្តបរិស័ទ។ ជាទូទៅ ការដឹកនាំបែបបង្គាប់បញ្ជាមានប្រសិទ្ធភាព នៅពេលដែលដឹកនាំអ្នកដទៃទៀតដែលមានបទពិសោធន៍តិចតួចនៅក្នុងភារកិច្ចដែលពួកគេកំពុងត្រូវបានសុំឲ្យធ្វើ រីឯការដឹកនាំបែបសម្របសម្រួល មានប្រសិទ្ធភាពច្រើនជាងជាមួយមនុស្សដែលមានចំណេះដឹង និងបទពិសោធន៍ច្រើនជាមួយភារកិច្ចដែលពួកគេកំពុងត្រូវបានសុំឲ្យធ្វើ។ ជាញឹកញាប់ របៀបដឹកនាំនឹងប្រែប្រួលស្របទៅតាមការងារជាក់ស្ដែង និងកម្រិតបទពិសោធន៍របស់អ្នកដែលចូលរួម។ ទោះបីយ៉ាងណាក៏ដោយ វិញ្ញាណនៅក្នុងការដឹកនាំតាមរបៀបណាក៏ដោយ គួរតែបង្ហាញចេញជាសេចក្ដីស្រលាញ់ចំពោះព្រះជាម្ចាស់ និងសេចក្ដីស្រលាញ់ចំពោះមនុស្ស។

| អ្នកដឹកនាំដែលបង្គាប់បញ្ជា | អ្នកដឹកនាំដែលសម្របសម្រួល |
| --- | --- |
| ផ្ដោតលើការងារ<br>«សម្រេចកិច្ចការ» | ផ្ដោតលើមនុស្ស:<br>«ឲ្យមនុស្សចូលរួម» |
| អ្នកធ្វើ | អ្នកបែកចែកភារកិច្ច |
| គោលដៅ:<br>«ធ្វើកិច្ចការរបស់ព័ន្ធកិច្ច» | គោលដៅ:<br>«បំពាក់បំប៉នអ្នកដទៃឲ្យបម្រើព័ន្ធកិច្ច» |
| អ្នកអនុវត្តន៍ | អ្នកបំពាក់បំប៉ន<br>អ្នកជួយឲ្យមានសម្ថភាព គ្រូបង្វឹក |

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរសួរថា: តើ«ការដឹកនាំដែលបង្គាប់បញ្ជា» ឬ «ការដឹកនាំដែលសម្របសម្រួល» មានប្រយោជន៍ច្រើនជាងសម្រាប់គ្រិស្តបរិស័ទ?។ ចូរសុំម្នាក់ឲ្យប្រាប់ឧទាហរណ៍អំពីស្ថានភាពមួយដែលត្រូវការការដឹកនាំដែលបង្គាប់បញ្ជា។ បន្ទាប់មក ចូរសុំម្នាក់ទៀតឲ្យប្រាប់ឧទាហរណ៍អំពីស្ថានភាពមួយដែលត្រូវការការដឹកនាំដែលសម្របសម្រួល។

ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន (១០ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរឲ្យសិក្ខាកាមម្នាក់ៗឆ្លុះបញ្ចាំងសំណួរខាងក្រោម ហើយសរសេរការឆ្លើយតបខ្លីមួយ។ នៅពេលដែលគ្រប់គ្នាចប់ហើយ ចូរចែកចាយចម្លើយមួយចំនួនតូចរបស់សំណួរនីមួយៗដោយសង្ខេបនៅក្នុងក្រុមធំ។

- តើមនុស្សក្លាយជាអ្នកដឹកនាំនៅក្នុងវប្បធម៌របស់លោកអ្នកយ៉ាងដូចម្ដេច?

___

___

- ហេតុអ្វីបានជាអ្នកដឹកនាំទាំងអស់ត្រូវតែជាអ្នកដើរតាមល្អជាមុនសិន?

___

___

- តើការយល់ថា «សិទ្ធិអំណាចដឹកនាំរបស់លោកអ្នកមកពីព្រះ» ផ្លាស់ប្ដូរទស្សនៈរបស់លោកអ្នកអំពីការដឹកនាំយ៉ាងដូចម្ដេច?

___

___

- តើមានឱកាសអ្វីខ្លះដែលកំពុងត្រូវបានចាត់ឡើង នៅពេលដែលអ្នកជឿថ្មីដែលមានសមត្ថភាពដឹកនាំពីកំណើតបានទទួលតួនាទីដឹកនាំនៅក្នុងក្រុមជំនុំ?

- តើតួនាទីដឹកនាំមួយណាខ្លះក្នុងចំណោមតួនាទីដឹកនាំនៅក្នុងសញ្ញាថ្មីដែលទូទៅបំផុតសម្រាប់លោកអ្នក?

- តើគោលគំនិតនៅក្នុងព្រះគម្ពីរទាំងនេះអំពីការដឹកនាំខុសពីគោលការណ៍ខាងលោកិយអំពីការដឹកនាំតាមវិធីណាខ្លះ?

ករណីសិក្សា (១០ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរចែកសិក្ខាកាមទៅជាក្រុមតូច។ បែងចែកករណីសិក្សាឲ្យក្រុមនីមួយៗ។ សម្រាប់ករណីសិក្សានីមួយៗ ចូរឲ្យក្រុមសម្រេចចិត្តអំពីរបៀបដែលពួកគេនឹងឲ្យយោបល់អ្នកដឹកនាំ ប្រសិនបើត្រូវបានទូរស័ព្ទមកសុំយោបល់។ ដើម្បីបញ្ចប់ម៉ោងនេះ ចូរឲ្យក្រុមតូចនីមួយៗរាយការណ៍ការងាររបស់ពួកគេប្រាប់ក្រុមធំ និងដឹកនាំការពិភាក្សាខ្លីអំពីការឆ្លើយតបរបស់ក្រុមនីមួយៗ។ កំណត់សម្គាល់: លោកអ្នកមិនចាំបាច់ប្រើករណីសិក្សាទាំងអស់ដែលបានផ្តល់ឲ្យទេ ចូរផ្លាស់ប្តូរចំនួនករណីសិក្សាដែលត្រូវប្រើទៅតាមចំនួនក្រុមដែលស័ក្តិសមសម្រាប់ទំហំថ្នាក់របស់លោកអ្នក។

១. លោកយ៉ូសែបកំពុងដឹកនាំគម្រោងដាំក្រុមជំនុំមួយនៅក្រុងកាំប៉ាឡា។ សារ៉ា និងរស់គឺជាសមាជិកក្រុមរយៈពេលបីខែមកហើយ។ នៅពេលថ្មីៗនេះ សារ៉ា និងរស់ចាប់ផ្តើមមានអារម្មណ៍បាក់ទឹកចិត្តយ៉ាងខ្លាំងជាមួយនឹងព័ន្ធកិច្ច។ ពួកគេមានគំនិតល្អៗមួយចំនួនសម្រាប់ការផ្សាយដំណឹងល្អ ប៉ុន្តែពួកគេមានអារម្មណ៍ថាគ្មានសេរីភាពនឹងនិយាយចេញគំនិតរបស់ខ្លួនទេ។ លោកយ៉ូសែប ជាអ្នកដឹកនាំរបស់ពួកគេ ហាក់បីដូចជាមិនព្រមស្តាប់យោបល់របស់ពួកគេទេ។ ផ្ទុយទៅវិញ គាត់ប្រាប់ពួកគេពីអ្វីដែលពួកគេគួរធ្វើ និងរបៀបដែលពួកគេគួរតែធ្វើ។ ជាលទ្ធផល សារ៉ា និងរស់កំពុងគិតចង់ចាកចេញពីព័ន្ធកិច្ច ហើយចាប់ផ្តើមព័ន្ធកិច្ចដោយខ្លួនឯង។ **តើលោកអ្នកនឹងវាយតម្លៃការដឹកនាំរបស់លោកយ៉ូសែបយ៉ាងដូចម្តេច?**

២. លោក រ៉ូប៊ើតូដឹកនាំក្រុមមួយដែលមានបីគ្រួសារនៅក្នុងការដាំក្រុមជំនុំមួយនៅក្រុងម៉ាឌ្រីត។ លោករ៉ូប៊ើតូពូកែអធិប្បាយនៅក្នុងអំឡុងពេលថ្វាយបង្គំរៀងរាល់ព្រឹកថ្ងៃអាទិត្យ ហើយគាត់ដឹកនាំក្រុមកោសិកានៅពាក់កណ្តាលសប្តាហ៍ដែលមានសមាជិកស្មោះត្រង់ឡើងដល់ជិត ២០ នាក់។ គ្រប់គ្នាចូលចិត្តសមត្ថភាពបង្រៀន និងអធិប្បាយព្រះបន្ទូលរបស់លោករ៉ូប៊ើត ព្រមទាំងសមត្ថភាពរៀបចំសកម្មភាពរបស់គាត់ផងដែរ។ ទោះបី យ៉ាងណាក៏ដោយ លោករ៉ូប៊ើតូកំពុងចាប់ផ្តើមមានអារម្មណ៍អស់កម្លាំងដោយសារការងារច្រើនពេក។ លោករ៉ូប៊ើតូបានសុំសមាជិករួមក្រុមគឺ លោកម៉ៃយល ឲ្យចាប់ផ្តើមក្រុមតូចថ្មី ដោយមានមនុស្សជាច្រើនមកពីក្រុមរបស់លោករ៉ូប៊ើតូ ប៉ុន្តែមានការចាប់អារម្មណ៍តិចតួច ដែលធ្វើឲ្យលោកម៉ៃយលបាក់ទឹកចិត្តយ៉ាងខ្លាំង។ **ចូរវាយតម្លៃរបៀបដែលលោករ៉ូប៊ើតូផ្ទេរការទទួលខុសត្រូវទៅឲ្យលោកម៉ៃយល។**

៣. ក្រុមជំនុំថ្មីមួយនៅផ្នែកខាងត្បូងនៃតំបន់ឡូរ៉េតូកំពុងមានការរីកចម្រើនឡើងយ៉ាងលឿន។ មនុស្សជាច្រើននិយាយថា ការរីកចម្រើនឡើងនេះគឺដោយសារតែការដឹកនាំយ៉ាងល្អរបស់អាល់ហ្វ្រ៊ែដូ និងអេណា។ ពួកគេបានចាប់ផ្តើមក្រុមជំនុំនេះ ក្រោយពីអាល់ហ្វ្រ៊ែដូបានត្រឡប់មកពីសាលាព្រះគម្ពីរនៅក្រុងលីម៉ាវិញ។ អ្នកដែលមកចូលរួមថ្វាយបង្គំភាគច្រើនគឺជាអ្នកជឿថ្មីដែលមិនមានប្រវត្តិក្រុមជំនុំពីមុនមកទាល់តែសោះ។ អាល់ហ្វ្រ៊ែដូអធិប្បាយភាគច្រើន ហើយអេណារៀបចំកម្មវិធីសាលាថ្ងៃអាទិត្យ។ នៅពេលដែលពួកគេបានរីកចម្រើនឡើង អាល់ហ្វ្រ៊ែដូបានសម្លឹងរកមើលអ្នកដឹកនាំថ្មីដើម្បីជួយគាត់នៅក្នុងការងារក្រុមជំនុំ។ ប៉ុន្តែ ហាក់បីដូចជាគ្មានអ្នកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីដឹកនាំទេ។ គាត់មានអារម្មណ៍ថាមានពរណាស់ដែលមានយុវជនបីនាក់ដែលអាចទទួលការហ្វឹកហ្វឺនដើម្បីធ្វើជាអ្នកដឹកនាំក្រុមជំនុំបាន។ អាល់ហ្វ្រ៊ែដូរក

បានអាហាររូបករណ៍ដើម្បីបញ្ជូនយុវជនពីរនាក់ទៅរៀនសាលាព្រះគម្ពីរនៅក្រុងលីម៉ា។ ពួកគេចាកចេញទៅនៅរដូវក្រដាក់ ដើម្បីចាប់ផ្តើមកម្មវិធីសិក្សាដែលមានរយៈពេលបីឆ្នាំ។ **តើលោកអ្នកនឹងវាយតម្លៃវិធីសាស្ត្រអភិវឌ្ឍន៍អ្នកដឹកនាំនេះយ៉ាងដូចម្តេច?**

៤. អ័កបារស់នៅក្នុងភូមិតូចមួយនៅប្រទេសតណ្ហាភាគខាងជើងដែលមិនមានក្រុមជំនុំដំណឹងល្អទេ។ នៅពេលថ្មីៗនេះ អ័កបាបានដឹងថា អ្នកជឿជាច្រើននៅក្នុងភូមិរបស់លោកធ្វើដំណើរមកកន្លែងផ្សេងៗគ្នា ដើម្បីចូលរួមថ្វាយបង្គំនៅក្នុងក្រុមជំនុំ។ អ្នកខ្លះនៅឆ្ងាយរហូតដល់ ៣០ គីឡូម៉ែត្រ។ នៅក្រោមការដឹកនាំរបស់អ័កបា អ្នកជឿត្រូវបានរៀបចំទៅជាក្រុមជំនុំថ្មីមួយ។ នៅពេលដែលអ្នកជឿជួបជុំគ្នា ពួកគេសុទ្ធតែរំភើបចិត្តអំពីក្រុមជំនុំមូលដ្ឋាន ហើយពួកគេនាំគ្នាចែកចាយអំពីរបៀបដែលក្រុមជំនុំគួរតែត្រូវបានរៀបចំឡើងដោយផ្អែកលើបទពិសោធន៍របស់ពួកគេនៅក្នុងក្រុមជំនុំមុនៗ។ ប៉ុន្តែ អ័កបាបញ្ជាក់យ៉ាងច្បាស់ថា គាត់នឹងធ្វើជាគ្រូគង្វាល ហើយមនុស្សគួរតែបំភ្លេចអំពីទំនៀមទម្លាប់ ឬរបៀបនៅក្នុងក្រុមជំនុំដើមរបស់ពួកគេ ពីព្រោះគាត់គឺជាអ្នកគ្រប់គ្រងក្នុងនាមជាគ្រូគង្វាលរបស់ក្រុមជំនុំនេះ។ **តើលោកអ្នកគិតថា វិធីសាស្ត្ររបស់អ័កបានឹងមានលទ្ធផលយ៉ាងដូចម្តេច?**

៥. ចាកគេសបានដាំក្រុមជំនុំបីកន្លែងនៅក្រុងផ្សេងៗគ្នាក្នុងប្រទេសប៊ីគីណា ហ្វាសូ ភាគខាងលិច។ លោក ចាកគេសគឺជាអ្នកមានអំណោយទានដាំក្រុមជំនុំ។ គាត់ស្វាហាប់ ចូលចិត្តដើរ និងមានអំណោយទានជាអ្នកផ្សាយដំណឹងល្អ។ គាត់ចេះលេងហ្គីតា ច្រៀង និងលេងកម្សាន្តជាមួយមនុស្សរាប់ម៉ោង។ គាត់ចូលចិត្តចាប់ផ្តើមអ្វីៗ បន្ទាប់មកបន្តទៅរកអ្វីមួយផ្សេងទៀត។ ក្រុមជំនុំដែលគាត់ចាប់ផ្តើមហាក់បីដូចជាយកតម្រាប់តាមបុគ្គលិកលក្ខណៈរបស់គាត់។ ពួកគេរំភើបចិត្តពីដំបូង ហើយចាប់ផ្តើមខ្សោយទៅ នៅពេលដែលមានអ្វីផ្សេងទៀតដែលរំភើបចិត្តជាង។ ចាកគេសនិយាយថា នេះគឺជាបុគ្គលិកលក្ខណៈរបស់គាត់ ហើយគាត់មិនអាចផ្លាស់ប្តូរបានទេ។ គាត់ដឹងថាព្រះជាម្ចាស់ប្រើគាត់ ទោះបីជាបែបនេះក៏ដោយ។ **តើលោកអ្នកនឹងវាយតម្លៃការដឹកនាំរបស់ចាកគេសយ៉ាងដូចម្តេច?**

៦. លោក ចន កំពុងខំប្រឹងប្រែងធ្វើការយ៉ាងខ្លាំងនៅក្នុងក្រុមជំនុំដែលគាត់បានដាំនៅក្រុងស៊ីឌនីអស់រយៈពេលជាច្រើនឆ្នាំ។ ក្រុមជំនុំកំពុងដំណើរការទៅយ៉ាងល្អ។ ក្រុមជំនុំបានរីកចម្រើនឡើងដល់ជិត ២០០ នាក់នៅក្នុងរយៈពេលបីឆ្នាំកន្លងមក។ ពេលខ្លះ ប្រពន្ធរបស់គាត់ និងកូនទាំងបួននាក់មិនបានឃើញគាត់អស់រយៈពេលជាច្រើនថ្ងៃ ពីព្រោះគាត់ចាកចេញទៅតាំងពីព្រលឹម ហើយត្រឡប់មកវិញនៅពេលយប់។ លោក ចន មិនចូលចិត្តរស់នៅបែបនេះទេ ប៉ុន្តែសមាជិករបស់គាត់ត្រូវការគាត់ខ្លាំងណាស់។ មានមនុស្សជាច្រើនឈឺត្រូវទៅសួរសុខទុក្ខ និងមានអ្នកអត់ផ្ទះសម្បែងដែលត្រូវការការយកចិត្តទុកដាក់ជាងរាប។ លោក ចន ដឹងថា ប្រសិនបើគាត់ឈប់ធ្វើកិច្ចការទាំងងស់ដែលគាត់កំពុងធ្វើ ព័ន្ធកិច្ចនឹងមានបញ្ហា មនុស្សនឹងមិនបានទទួលសេចក្តីសង្គ្រោះ ហើយក្រុមជំនុំនឹងមិនរីកចម្រើនឡើងទៀតទេ។ **តើលោកអ្នកគិតថា ចនគឺជាអ្នកដឹកនាំល្អដែរឬទេ? ល្អ ហេតុអ្វី មិនល្អ ហេតុអ្វី?**

# ម៉ោងទី ៣
# ការផ្សាយដំណឹងល្អ និងការដាំក្រុមជំនុំ (៦០ នាទី)

របាយការណ៍អំពីផែនការសកម្មភាពសម្រាប់ម៉ូឌុល ៤ (៣០ នាទី)
ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរចែកទៅជាក្រុមដែលមានគ្នា ៣ ឬ ៤ នាក់។ ចូរឲ្យម្នាក់ៗចែកចាយបទពិសោធន៍របស់ពួកគេអំពីការធ្វើការជាមួយគ្រូគង្វាល និងក្រុមជំនុំដែលឧបត្ថម្ភពួកគេ ព្រមទាំងអ្នកដែលពាក់ព័ន្ធនៅក្នុងការដាំក្រុមជំនុំ ដើម្បីកែលម្អនិមិត្ត បេសកកម្ម គុណតម្លៃស្នូល និងយុទ្ធសាស្ត្ររបស់ពួកគេ។ តើមានអ្វីខ្លះត្រូវបានបញ្ជាក់អះអាង ហើយហេតុអ្វី? តើបានធ្វើការផ្លាស់ប្តូរអ្វីខ្លះ ហើយហេតុអ្វី? ចូរដឹកនាំការសួរនាំជាក្រុមធំអំពីការពិភាក្សានៅក្នុងក្រុមតូច។

គោលការណ៍អំពីការផ្សាយដំណឹងល្អសម្រាប់អ្នកដាំក្រុមជំនុំ (២០ នាទី)
ការណែនាំសម្រាប់អ្នកសម្របសម្រួល: ដោយប្រើមេរៀនខាងក្រោម ចូរដឹកនាំការពិភាក្សាជាក្រុមធំទាក់ទងនឹងគោលការណ៍អំពីការផ្សាយដំណឹងល្អសម្រាប់អ្នកដាំក្រុមជំនុំ។ ចូរឲ្យសិក្ខាកាមម្នាក់ៗបំពេញនៅក្នុងគ្រោងដែលមាននៅក្នុងសៀវភៅលំហាត់របស់ពួកគេ។

ក. ប្រើការផ្សាភ្ជាប់ពីកំណើតនៅក្នុងចំណោមមនុស្ស
តើព្រះយេស៊ូបានប្រើបណ្តាញទំនាក់ទំនងអ្វីខ្លះនៅក្នុងការត្រាស់ហៅអ្នកដើរតាមព្រះអង្គ? យ៉ូហាន ១:៤០-៤១, ៤:២៨-៣០ លូកា ៨:៣៨-៣៩

ខ. អ្នកជឿថ្មីធ្វើទីបន្ទាល់ភ្លាមៗ
ហេតុអ្វីបានជាអ្នកជឿថ្មីគឺជាអ្នកផ្សាយដំណឹងល្អដ៏មានប្រសិទ្ធភាព? ចម្លើយមួយចំនួនដើម្បីពិភាក្សារួមជាមួយនឹងចម្លើយរបស់លោកអ្នក:
- ជំនឿរបស់ពួកគេនៅថ្មី។
- អ្នកជឿថ្មីនៅមានមិត្តភក្តិដែលមិនជឿដែលអាចមើលឃើញការផ្លាស់ប្តូរ។

គ. ចូរទៅរកឆ្នាំទ្វារ
តើឆ្នាំទ្វារគឺជានរណា?
អ្នកដែលមានឥទ្ធិពល ឬសិទ្ធិអំណាចលើអ្នកដទៃទៀតត្រូវបានចាត់ទុកថាជា«ឆ្នាំទ្វារ» ពីព្រោះការដែលពួកគេស្គាល់ព្រះគ្រិស្តអាចបើកទ្វារឲ្យមនុស្សដទៃទៀតទទួលយកព្រះអង្គបាន។

ហេតុអ្វីបានជាត្រូវខំប្រឹងប្រែងកាន់តែខ្លាំងដើម្បីឈោងចាប់ពួកគេ? ចូរពិភាក្សាអំពីចម្លើយនេះរួមជាមួយនឹងចម្លើយដទៃទៀត។
ការផ្សារភ្ជាប់ពីកំណើត – ភ្លាមៗ – ឆ្នាំទ្វារ
អ្នកដែលកាន់តែមានឥទ្ធិពលធ្វើដំណើរទៅរកព្រះគ្រិស្តកាន់តែយឺត ប៉ុន្តែឥទ្ធិពលយូរអង្វែងរបស់ពួកគេសម្រាប់ដំណឹងល្អអាចកាន់តែធំ។ ចេញពីបទគម្ពីរទាំងនេះ ចូរប្រាប់ឈ្មោះឧទាហរណ៍មួយចំនួនរបស់«ឆ្នាំទ្វារ» (កិច្ចការ ១៦:១១-១៥, ១៧:១-៩, ១៨:៧-៨)។

ឃ. ចូរពិចារណាឧបសគ្គខាងវប្បធម៌។
តើមនុស្សឆ្លងឧបសគ្គខាងវប្បធម៌យ៉ាងដូចម្តេច? ហេតុអ្វីបានជាដូច្នេះ?
តើលោកអ្នកអាចចាប់ផ្តើមក្រុមជំនុំឲ្យត្រូវនឹងមនុស្សដែលលោកអ្នកកំពុងព្យាយាមឈោងចាប់បានយ៉ាងដូចម្តេច? (១ កូរិនថូស ៩:២០-២៣)

ឃ. ចូរស្វែងរកមូលដ្ឋានគ្រឹះរួម។
តើសកម្មភាពមួយចំនួនដែលទូទៅសម្រាប់អ្នកជឿ និងអ្នកមិនជឿ មានអ្វីខ្លះ?

## ផែនការសកម្មភាពសម្រាប់ម៉ូឌុល ៥ (១០ នាទី)

មុនពេលត្រឡប់មករៀនម៉ូឌុល ៥ ចូរប្រើទម្រង់ផែនការមេរបស់ខ្ញុំនៅក្នុងការដាំក្រុមជំនុំ ដែលបានផ្ដល់ឲ្យនៅខាងក្រោម ដើម្បីចងក្រងផែនការមេជាលាយលក្ខណ៍អក្សរសម្រាប់ក្រុមជំនុំថ្មីដែលលោកអ្នកបានដាំ។ សិក្ខាកាមគួរតែជួបជាមួយក្រុមជំនុំដែលឧបត្ថម្ភពួកគេ ព្រមទាំងគ្រូគង្វាល ឬគ្រូឧបជ្ឈា ដើម្បីឯកភាពនឹងផែនការនេះ មុនមករៀនម៉ូឌុល ៥។

ឧបសគ្គ – មូលដ្ឋានគ្រឹះរួម

COMMON GROUND

# ផែនការមេនៅក្នុងការដាំក្រុមជំនុំ
# សម្រាប់

___________________________________________
(ឈ្មោះក្រុមមនុស្សគោលដៅ ចំនួនប្រជាជន ឬទីតាំងភូមិសាស្ត្រ)

រៀបចំឡើងដោយ

___________________________________________
(ឈ្មោះរបស់លោកអ្នក)

គាំទ្រ និងឧបត្ថម្ភដោយ

___________________________________________
(ឈ្មោះគ្រូគង្វាល ឬគ្រូឧបជ្ឈាដែលគាំទ្រលោកអ្នក)

___________________________________________
(កាលបរិច្ឆេទដែលឯកសារនេះបានទទួលការឯកភាពពីក្រុមជំនុំ និងគ្រូគង្វាលដែលគាំទ្រលោកអ្នក)

I. ការស្រាវជ្រាវៈ អ្វីដែលព្រះជាម្ចាស់បានបង្ហាញខ្ញុំអំពីមនុស្សគោលដៅរបស់ខ្ញុំ ចំនួនប្រជាជន ឬតំបន់

ក. កាពណ៌នាទូទៅៈ

___________________________________________
___________________________________________
___________________________________________

ខ. ឱកាស ឬទ្វារបើកចំហសម្រាប់ដំណឹងល្អដែលបានរកឃើញៈ

___________________________________________
___________________________________________
___________________________________________

គ. ឧបសគ្គរារាំងដំណឹងល្អ និងរបៀបដែលអាចយកឈ្នះបានៈ

___________________________________________
___________________________________________
___________________________________________

ឃ. ការពិតសំខាន់ៗដែលនឹងប្រាប់អំពីការខំប្រឹងប្រែងដាំក្រុមជំនុំរបស់ខ្ញុំៈ

១. ___________________________________________
២. ___________________________________________
៣. ___________________________________________
៤. ___________________________________________
៥. ___________________________________________

II. សេចក្តីថ្លែងការណ៍និមិត្ត

___________________________________________
___________________________________________
___________________________________________

ខគម្ពីរយោងដែលគាំទ្រសេចក្តីថ្លែងការណ៍និមិត្ត:

______________________________

______________________________

______________________________

III. សេចក្តីថ្លែងការណ៍បេសកកម្ម

______________________________

______________________________

______________________________

ខគម្ពីរយោងដែលគាំទ្រសេចក្តីថ្លែងការណ៍បេសកកម្ម:

______________________________

______________________________

______________________________

**IV.** សេចក្តីថ្លែងការណ៍គុណតម្លៃស្នូល

______________________________

______________________________

______________________________

ខគម្ពីរយោងដែលគាំទ្រសេចក្តីថ្លែងគុណតម្លៃស្នូល:

______________________________

______________________________

______________________________

V. ផែនការយុទ្ធសាស្រ្ត

ក. ការអធិស្ឋាន

១. ______________________________

២. ______________________________

៣. ______________________________

៤. ______________________________

៥. ______________________________

ខ. ការផ្សាយដំណឹងល្អ

១. ______________________________

២. ______________________________

៣. ______________________________

៤. ______________________________

៥. ______________________________

គ. ការបង្កើតសិស្ស

១. ______________________________

២. ______________________________

៣. ______________________________

៤. ______________________________

៥. ______________________________

ឃ. ការប្រកប (ការជួបជុំគ្នា)

១. ______________________________
២. ______________________________
៣. ______________________________
៤. ______________________________
៥. ______________________________

ង. ការអភិវឌ្ឍន៍អ្នកដឹកនាំ

១. ______________________________
២. ______________________________
៣. ______________________________
៤. ______________________________
៥. ______________________________

ច. ការថ្វាយបង្គំ

១. ______________________________
២. ______________________________
៣. ______________________________
៤. ______________________________
៥. ______________________________

ឆ. ការបម្រើ

១. ______________________________
២. ______________________________
៣. ______________________________
៤. ______________________________
៥. ______________________________

ជ. ពហុគុណ (បេសកកម្ម)

១. ______________________________
២. ______________________________
៣. ______________________________
៤. ______________________________
៥. ______________________________

______________________ ______________________

គ្រូគង្វាល អ្នកព្រោះ

______________________

តំណាងក្រុមជំនុំ

ហត្ថលេខា និងកាលបរិច្ឆេទនេះបញ្ជាក់អះអាងថា ក្រុមជំនុំ និងគ្រូគង្វាលដែលគាំទ្រលោកអ្នក ឬគ្រូឧបជ្ឈាយ៍របស់លោកអ្នកឯកភាព និងគាំទ្រផែនការដាំក្រុមជំនុំនេះ។

អាហារថ្ងៃត្រង់ (៦០ នាទី)

# ម៉ោងទី ៤
# ការចាប់ផ្ដើមក្រុមតូច (៦០ នាទី)

## ការបង្រៀន & ការពិភាក្សា (២០ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួលៈ ចូរប្រើមេរៀនខាងក្រោម ដើម្បីដឹកនាំការពិភាក្សាជាក្រុមធំ អំពីការចាប់ផ្ដើមក្រុមតូច។ ចូរឲ្យសិក្ខាកាមបំពេញគ្រោងនៅក្នុងសៀវភៅលំហាត់របស់ពួកគេនៅក្នុងអំឡុងពេលនៃការពិភាក្សា។

ចូរដឹកនាំក្រុមពិចារណាអំពីមូលហេតុដែលចំណុចនីមួយៗក្នុងចំណោមខាងក្រោមមានសារៈសំខាន់នៅក្នុងការចាប់ផ្ដើមក្រុមតូចៈ

១. រៀបចំសម្រាប់ក្រុមកោសិកាថ្មី
   ក. បង្កើតក្រុមអធិស្ឋាន (អេភេសូរ ៦:១៩, ១ ថែស្សាឡូនីច ៥:២៥)
   ខ. បង្កើតក្រុមអ្នកដឹកនាំ (លូកា ១០:១)
   គ. ស្រាវជ្រាវតំបន់គោលដៅរបស់លោកអ្នក

២. បង្កើតទំនាក់ទំនង
   ក. តើមនុស្សគោលដៅរបស់លោកអ្នកគឺជានរណា?
   ខ. តើលោកអ្នកអាចបង្កើតទំនាក់ទំនងជាមួយពួកគេបានយ៉ាងដូចម្ដេច?

៣. ជ្រើសរើសទីតាំង
   ក. តើទីតាំងសមរម្យសម្រាប់ក្រុមកោសិកសារបស់លោកអ្នកជួបជុំគ្នាគឺជាអ្វី?

៤. រៀបចំសម្រាប់ការជួបប្រជុំដំបូង
   ក. តើបញ្ហាមិនធម្មតាមួយចំនួនដែលលោកអ្នកអាចមាន នៅពេលដែលលោកអ្នកកំពុង «ត្រួសត្រាយផ្លូវ»សម្រាប់ការដាំក្រុមជំនុំនៅក្នុងតំបន់ដែលមិនមានទីបន្ទាល់គ្រិស្តបរិស័ទមានអ្វីខ្លះ?
   ខ. តើអាចធ្វើអ្វីបាន ដើម្បីយកឈ្នះឧបសគ្គទាំងនេះ?
   គ. តើលោកអ្នកនឹងនិយាយយ៉ាងដូចម្ដេចទៅកាន់អ្នកជឿដែលជាសមាជិកនៅក្នុងក្រុមកោសិការបស់លោកអ្នក ប៉ុន្តែខ្លាចមិនហ៊ានបើកទ្វារផ្ទះខ្លួនទទួលភ្ញៀវដែលគេមិនស្គាល់?

## ទម្រង់នៃការរៀបចំផែនការក្រុមតូច (៤០ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួលៈ ចូរឲ្យសិក្ខាកាមម្នាក់ៗប្រើទម្រង់នៃការរៀបចំផែនការក្រុមតូច ដើម្បីបង្កើតផែនការសម្រាប់ការជួបប្រជុំក្រុមតូច។ ប្រសិនបើអាចធ្វើបាន ចូរឲ្យសេចក្ដីចម្លងទម្រង់នេះដល់សិក្ខាកាម ដើម្បីឲ្យសិក្ខាកាមនៅមានទម្រង់ដែលទទេស្អាតនៅក្នុងសៀវភៅលំហាត់របស់ពួកគេ។ បន្ទាប់មក សិក្ខាកាមអាចប្រើទម្រង់ដែលទទេស្អាតនេះដើម្បីថតចម្លងសម្រាប់រៀបចំផែនការការជួបប្រជុំក្រុមតូចបន្តទៀត។

រៀបចំ - ក្រុមអធិស្ឋាន - ក្រុមអ្នកដឹកនាំ - ស្រាវជ្រាវ - ទំនាក់ទំនង - មនុស្ស - ទំនាក់ទំនង - ទីតាំង - សមរម្យ - រៀបចំ

១. នៅក្នុងការរៀបចំផែនការ តើផ្នែកអ្វីដែលងាយស្រួលបំផុតសម្រាប់លោកអ្នក? ហេតុអ្វី?
២. តើផ្នែកអ្វីដែលពិបាកបំផុត? ហេតុអ្វី?
៣. តើលោកអ្នកនឹងធ្វើអ្វី ប្រសិនបើលោកអ្នកមិនអាចរកបានអ្នកដែលព្រមនិងដែលមានសមត្ថភាពដឹកនាំក្រុមច្រៀងបាន?
៤. តើលោកអ្នករំពឹងទុកថា ផ្នែកអ្វីខ្លះក្នុងការជួបប្រជុំក្រុមតូចដែលនឹងដំណើរការទៅល្អបំផុត? ចូរពន្យល់។
៥. តើលោកអ្នករំពឹងទុកថា ផ្នែកអ្វីខ្លះដែលនឹងដំណើរការទៅមិនល្អសោះ? ចូរពន្យល់។

*ទម្រង់នៃការរៀបចំផែនការក្រុមតូច*

| |
|---|
| កាលបរិច្ឆេទ និងពេលវេលានៃការជួបប្រជុំ: ______________________<br>ទីតាំង និងអ្នករៀបចំ: ______________________ |
| ការប្រកប |
| អាហារសម្រន់: ______________________<br>សកម្មភាព ល្បែងកម្សាន្ត: ______________________ |
| ការថ្វាយបង្គំ |
| អ្នកដឹកនាំចម្រៀង: ______________________ |
| ការអធិស្ឋាន |
| អ្នកអធិស្ឋាន: ______________________ |
| ការពិភាក្សាព្រះគម្ពីរ |
| អ្នកដឹកនាំការពិភាក្សា: ______________________<br>បទគម្ពីរ: ______________________ |
| ការនិមិត្តឃើញព័ន្ធកិច្ច |
| ពេលវេលាចែកចាយ: ______________________<br>សកម្មភាព: ______________________ |

ការណែនាំសម្រាប់អ្នកសម្របសម្រួល: នៅក្នុងរយៈពេល ១០ ចុងក្រោយនៃម៉ោងសិក្សានេះ ចូរប្រើសំណួរខាងក្រោមដើម្បីពិភាក្សាអំពីសកម្មភាពការរៀបចំផែនការរបស់បុគ្គល។

## កិច្ចការដែលត្រូវគិត:

- តើអ្នកដឹកនាំហាត់ការរបស់លោកអ្នកគឺជានរណា?
- តើនរណាកំពុងបង្រៀនសមាជិកម្នាក់ៗនៅក្នុងក្រុមរបស់លោកអ្នក?
  (តើលោកអ្នកកំពុងបង្រៀននរណា?)
- តើលោកអ្នកកំពុងធ្វើអ្វី ដើម្បីជួយអ្នកដឹកនាំហាត់ការរបស់លោកអ្នកអភិវឌ្ឍជំនាញដឹកនាំ? តើលោកអ្នកកំពុងបែងចែកព័ន្ធកិច្ចឲ្យគេយ៉ាងដូចម្តេច? តើលោកអ្នកកំពុងធ្វើគំរូបម្រើព័ន្ធកិច្ចដល់គេយ៉ាងដូចម្តេច?
- តើលោកអ្នកកំពុងអធិស្ឋានឲ្យសមាជិកម្នាក់ៗនៅក្នុងក្រុមកោសិការបស់លោកអ្នកដែរឬទេ?

# ម៉ោងទី ៥
# ការផ្សាយដំណឹងល្អ និងការបំពេញសេចក្តីត្រូវការរបស់សហគមន៍ (៦០ នាទី)

## ទំនាក់ទំនងបីប្រភេទរវាងការបម្រើ និងការផ្សាយដំណឹងល្អ (១០ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរណែនាំអំពីទំនាក់ទំនងបីប្រភេទរវាងការបម្រើ និងការផ្សាយដំណឹងល្អ។ ចូរឲ្យសិក្ខាកាមម្នាក់ៗបំពេញគ្រោងនៅក្នុងសៀវភៅលំហាត់របស់ពួកគេ។

១. ព័ន្ធកិច្ចជា**លទ្ធផល**របស់ការផ្សាយដំណឹងល្អ: ការប្រែចិត្តជឿព្រះគ្រិស្តធ្វើឲ្យយើងយកចិត្តទុកដាក់ចំពោះសេចក្តីត្រូវការរបស់អ្នកដទៃទៀត ហើយចង់បំពេញសេចក្តីត្រូវការទាំងនោះ។

________________________________________

________________________________________

________________________________________

២. ព័ន្ធកិច្ចជា**ស្ពាន**សម្រាប់ការផ្សាយដំណឹងល្អ: ការបម្រើអ្នកដទៃទៀតជាចំណុចចាប់ផ្តើមដែលក្រោយមកធ្វើឲ្យពួកគេព្រមស្តាប់ដំណឹងល្អ។

________________________________________

________________________________________

________________________________________

៣. ព័ន្ធកិច្ច**អមមកជាមួយ**ការផ្សាយដំណឹងល្អ: និយាយអំពីព្រះយេស៊ូ ខណៈពេលដែលកំពុងបម្រើអ្នកដទៃទៀត។

________________________________________

________________________________________

________________________________________

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរចែកទៅជាបីក្រុម។ ចូរបិតផ្ទាំងក្រដាសធំៗបីសន្លឹកលើជញ្ជាំងបីផ្សេងគ្នានៅក្នុងបន្ទប់។ ចូរដាក់ឈ្មោះសន្លឹកទី ១ ថា «លទ្ធផល» សន្លឹកទី ២ ថា «ស្ពាន» និងសន្លឹកទី ៣ ថា «អមមកជាមួយ»។ ចូរបែងចែកឲ្យក្រុមនីមួយៗមួយសន្លឹក។ ចូរឲ្យក្រុមទៅកាន់ផ្ទាំងក្រដាសនោះ ហើយបំផុសគំនិតឲ្យបានច្រើនអំពីសកម្មភាពបម្រើ និងការផ្សាយដំណឹងល្អដែលពួកគេអាចគិតឃើញសម្រាប់ទំនាក់ទំនងដែលបានបែងចែកឲ្យពួកគេ។ ដប់នាទីក្រោយ ចូរឲ្យក្រុមចល័តតាមទ្រនិចនាឡិកាទៅកាន់ផ្ទាំងក្រដាសបន្ទាប់ ហើយធ្វើលំហាត់ឡើងវិញដោយបន្ថែមពីលើកិច្ចការរបស់ក្រុមមុន។ ចូរបន្តចល័តរៀងរាល់ ១០ នាទីម្តង រហូតដល់ក្រុមនីមួយៗបានរួមចំណែកសរសេរនៅលើផ្ទាំងក្រដាសទាំងបី។ ចូរប្រើពេល ១០ នាទីដែលនៅសល់ដើម្បីសួរនាំអំពីសកម្មភាពនេះនៅក្នុងក្រុមធំ។ ចូរបញ្ចប់ដោយទុកពេលនៅសល់ឲ្យសិក្ខាកាមត្រឡប់ទៅផ្ទាំងក្រដាស ហើយកត់ត្រាគំនិតដែលពួកគេជឿថាមានប្រយោជន៍ជាពិសេសសម្រាប់ពួកគេនៅក្នុងស្ថានភាពដាំក្រុមជំនុំរបស់ខ្លួនដាក់នៅក្នុងប្រឡោះដែលបានផ្តល់ឲ្យនៅក្នុងសៀវភៅលំហាត់របស់ពួកគេ។

លទ្ធផល — ស្ពាន — អមមកជាមួយ

## សម្រាក (១៥ នាទី)

# ម៉ោងទី ៦
# ការបកស្រាយព្រះបន្ទូល: ដោយប្រើការសិក្សាព្រះគម្ពីរបែបវិសេសានុមាន (៦០ នាទី)

## រំឭកឡើងវិញ (១៥ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរសុំសិក្ខាកាមឲ្យរៀបរាប់ឡើងវិញដំណាក់កាលទាំងបីរបស់ដំណើរការសិក្សាព្រះគម្ពីរបែបវិសេសានុមាន ដោយប្រើគ្រោងដែលបានផ្តល់ឲ្យនៅខាងក្រោម (មកពីម៉ូឌុល ១)។

ក. ការសង្កេតមើល – តើបទគម្ពីរប្រាប់នេះប្រាប់អំពីអ្វី?
ខ. ការបកស្រាយ – តើបទគម្ពីរនេះចង់មានន័យយ៉ាងដូចម្តេច?
គ. ការអនុវត្តន៍ – តើខ្ញុំគួរតែធ្វើអ្វី?

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរសុំសិក្ខាកាមឲ្យរៀបរាប់ឡើងវិញអំពីជំហានមូលដ្ឋានគ្រឹះនៅក្នុងដំណាក់កាលសង្កេតមើលរបស់ការសិក្សាព្រះគម្ពីរបែបវិសេសានុមាន ដោយប្រើគ្រោងដែលបានផ្តល់ឲ្យនៅខាងក្រោម (មកពីម៉ូឌុល ២)។

ក. ត្រៀមសម្រាប់ការសង្កេតមើល
ខ. ចំណាយពេលវេលាគ្រប់គ្រាន់
គ. មើលបរិបទ (ឬស្ថានភាព)
ឃ. ពិនិត្យមើលរចនាសម្ព័ន្ធ
ង. សួរសំណួរស៊ើបអង្កេត

## ការធ្វើបទបង្ហាញ (១៥ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ដោយប្រើទម្រង់ជាការបង្រៀន ចូរដឹកនាំសិក្ខាកាមបំពេញគ្រោងខាងក្រោមអំពីដំណាក់កាលបកស្រាយរបស់ការសិក្សាព្រះគម្ពីរបែបវិសេសានុមាន។

១. ការបកស្រាយ – ដំណាក់កាលទីពីររបស់វិធីសាស្ត្រវិសេសានុមាន

២. ដំណើរការវិសេសានុមាន
   I. ឆ្លុះបញ្ចាំងអំពីការពិតសំខាន់ៗដែលសង្កេតមើលឃើញនៅក្នុងបទគម្ពីរ
   II. កំណត់គំនិតចម្បងរបស់អ្នកនិពន្ធ
   III. កំណត់លំហូរគំនិតនៅក្នុងបទគម្ពីរ

**៣. ច្បាប់ជាមូលដ្ឋានគ្រឹះសម្រាប់ការបកស្រាយ**
   I. គោលការណ៍ទូទៅសម្រាប់ការបកស្រាយព្រះគម្ពីរ

ប្រាប់ - មានន័យ - ធ្វើ - ត្រៀម - ពេលវេលា - បរិបទ - រចនាសម្ព័ន្ធ - ស៊ើបអង្កេត - ការបកស្រាយ - វិសេសានុមាន - ការពិត - គំនិតចម្បង - លំហូរគំនិត

      ក. ព្រះគម្ពីរគឺជាព្រះបន្ទូលប្រកបដោយអំណាចសិទ្ធិរបស់ព្រះ។
      ខ. ព្រះគម្ពីរគឺជាអ្នកបកស្រាយដ៏ល្អបំផុតឲ្យខ្លួនឯង ដោយឆ្លុះបញ្ចាំងពីចរិតរបស់ព្រះ
      គ. ជំនឿដែលនាំឲ្យបានសង្គ្រោះ និងព្រះវិញ្ញាណបរិសុទ្ធចាំបាច់ណាស់ដើម្បីយល់បទគម្ពីរ។
      ឃ. លោកអ្នកគួរតែបកស្រាយប្រវត្តិសាស្ត្រ សកម្មភាព តរិយាបថ បទពិសោធន៍ផ្ទាល់ខ្លួន ។ល។ ដោយឆ្លុះបញ្ចាំងនឹងបទគម្ពីរ។
      ង. គោលបំណងចម្បងរបស់ព្រះគម្ពីរមិនមែនដើម្បីបង្កើនចំណេះដឹងរបស់យើងទេ ប៉ុន្តែដើម្បីផ្លាស់ប្តូរជីវិតរបស់យើងវិញ។
      ច. គ្រិស្តបរិស័ទទាំងអស់មានសិទ្ធិ ការទទួលខុសត្រូវ និងឯកសិទ្ធិស្វែងយល់ និងបកស្រាយព្រះបន្ទូលរបស់ព្រះដោយមានជំនួយរបស់ព្រះវិញ្ញាណបរិសុទ្ធ។

១. គោលការណ៍វេយ្យាករណ៍ ប្រវត្តិសាស្ត្រ និងទេវសាស្ត្រ នៅក្នុងការបក្រសាយព្រះគម្ពីរ
   ក. លោកអ្នកគួរតែបកស្រាយព្រះបន្ទូលស្របទៅតាមន័យព្រះបន្ទូលនៅក្នុងបរិបទប្រវត្តិសាស្ត្រ និងវប្បធម៌របស់អ្នកនិពន្ធ។ ចូរគិតជានិច្ចអំពីរបៀបដែលអ្នកស្តាប់ដើមយល់ និងមានប្រតិកម្មចំពោះព្រះរាជសារនេះ។
   ខ. វាជាការសំខាន់ណាស់ដែលត្រូវយល់វេយ្យាករណ៍របស់បទគម្ពីរ មុនពេលដែលព្យាយាមយល់

សេចក្តីពិតខាងទេវសាស្ត្រដែលបទគម្ពីរនោះបង្រៀន។

គ. ជាធម្មតា ភាសាប្រៀបធៀបមានគំនិតចម្បងមួយ។ កុំព្យាយាមគិតន័យច្រើនពេកនៅក្នុងបទគម្ពីរដែលប្រើរូបភាព ឬនិមិត្តសញ្ញាសម្រាប់គំនិត។

ឃ. លោកអ្នកគួរតែច្បាស់អំពីប្រធានបទមួយត្រឹមដែលបទគម្ពីរច្បាស់បានហើយ។ កុំបន្ថែមការគិតផ្ទាល់ខ្លួន ឬប្រពៃណីក្រុមជំនុំទៅក្នុងអ្វីដែលព្រះគម្ពីរប្រាប់ ដោយព្រោះលោកអ្នក ឬអ្នកដទៃទៀតជឿថា គំនិតទាំងនោះស្របតាមបទគម្ពីរនោះឡើយ។

២. កំហុសទូទៅនៅក្នុងការបកស្រាយដែលត្រូវចៀសវាង

ក. ក្តារលោត: លោតពីបទគម្ពីរមួយទៅគំនិត ឬការបង្រៀនមួយផ្សេងទៀតដែលលោកអ្នកចង់ពិភាក្សា។

ខ. អត្ថបដិរូប: ព្រងើយកន្តើយចំពោះអត្ថន័យដ៏ច្បាស់លាស់របស់បទគម្ពីរ ហើយព្យាយាមរកអត្ថន័យលាក់បាំង។

គ. ការព្រងើយកន្តើយចំពោះការបើកសម្តែងដែលកើនឡើងជាលំដាប់: បំភ្លេចលក្ខណៈកើនឡើងជាលំដាប់របស់បទគម្ពីរ។

ច្បាប់ – គោលការណ៍ – អាជ្ញាសិទ្ធិ - អ្នកបកស្រាយ - ព្រះវិញ្ញាណបរិសុទ្ធ - បទគម្ពីរ - ផ្លាស់ប្តូរជីវិត - សិទ្ធិ - ការទទួលខុសត្រូវ - ឯកសិទ្ធិ - ព្រះវិញ្ញាណបរិសុទ្ធ - វេយ្យាករណ៍ - ប្រវត្តិសាស្ត្រ – ទេវសាស្ត្រ – ប្រវត្តិសាស្ត្រ – វប្បធម៌ - ដើម - វេយ្យាករណ៍ - មួយ - កុំបន្ថែម - កំហុស – ក្តារលោត – អត្ថបដិរូប – ការព្រងើយកន្តើយចំពោះការបើកសម្តែងដែលកើនឡើងជាលំដាប់

CHANGE OUR LIVES - RIGHT - RESPONSIBILITY - PRIVILEGE - HOLY SPIRIT - GRAMMATICAL - HISTORICAL - THEOLOGICAL - HISTORICAL - CULTURAL - ORIGINAL - GRAMMAR - ONE - DO NOT ADD - ERRORS - SPRINGBOARD - ALLEGORY - IGNORING PROGRESSIVE REVELATION

ការអនុវត្តន៍នៅក្នុងក្រុមតូច (៣០ នាទី)
ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរចែកទៅជាក្រុមតូច ហើយធ្វើសកម្មភាពការហាត់បកស្រាយនៅខាងក្រោម។ ចូរសុំឲ្យមានអ្នកស្ម័គ្រចិត្តធ្វើជាអ្នកសម្របសម្រួលការសិក្សាសម្រាប់ក្រុមនីមួយៗ។ ការងាររបស់អ្នកសម្របសម្រួលគឺធ្វើឲ្យការសិក្សានៅក្នុងក្រុមដំណើរការទៅមុខ។ ចូរសួរនាំអំពីបទពិសោធន៍នេះតាមពេលវេលាដែលមាន។

ការណែនាំសម្រាប់ក្រុម: ចូរយោងត្រឡប់ទៅរកការសង្កេតមើលរបស់លោកអ្នកអំពីយេរេមា ១ ដែលបានធ្វើនៅក្នុងម៉ូឌុល ២ វិញ។ ចូរធ្វើតាមដំណើរការបកស្រាយ តាមពេលវេលាដែលមាន។ ចូរធ្វើតាមទម្រង់ដែលបង្ហាញប្រាប់នៅខាងក្រោម។

១. ចូររកការសង្កេតមើលគន្លឹះនៅក្នុងបទគម្ពីរ
២. ចូរប្រាប់គំនិតចម្បង
៣. ចូរពណ៌នាអំពីលំហូរគំនិត
៤. ចូរឆ្លុះបញ្ចាំងសំណួរមួយចំនួនអំពី«អត្ថន័យ»

នៅពេលដែលលោកអ្នកធ្វើតាមសេចក្ដីថ្លែងខាងលើ នោះមានប្រយោជន៍នឹងពិចារណាសំណួរខាងក្រោមអំពីអត្ថន័យរបស់បទគម្ពីរ។ លោកអ្នកប្រហែលជាគិតឃើញសំណួរល្អៗដទៃទៀត ឬប្រសើរជាងផង។ សំណួរទាំងនេះផ្ដល់មកដើម្បីឲ្យលោកអ្នកចាប់ផ្ដើមដំណើរការនេះ។

ខ ៥
តើព្រះអម្ចាស់«ស្គាល់»លោកយេរេមាមានន័យយ៉ាងដូចម្ដេច? តើ«ញែកជាបរិសុទ្ធ»មានន័យយ៉ាងដូចម្ដេច?
តើប្រយោគ «...កាលមុនដែលឯងសម្រាលចេញពីផ្ទៃមក នោះអញបានញែកឯងជាបរិសុទ្ធផង...» ប្រាប់ដោយប្រយោលអ្វីខ្លះ?

ខ ៦
ហេតុអ្វីបានជាលោកយេរេមាចាត់ទុកខ្លួនឯងថាជា«ក្មេង»?
តើលោកអ្នកគិតថា ហេតុអ្វីបានជាលោកយេរេមាបានឆ្លើយតបរបៀបនោះ?

ខ ៧
តើលោកអ្នកនឹងពណ៌នាការត្រាស់ហៅមកពីព្រះយ៉ាងដូចម្ដេច តាមរយៈអ្វីដែលលោកអ្នកមើលឃើញនៅក្នុងខគម្ពីរនេះ? តើចម្លើយរបស់លោកអ្នកសម្រាប់សំណួរមុនបង្ហាញប្រាប់យ៉ាងដូចម្ដេចអំពីព្រះនិងអត្តចរិតរបស់ព្រះអង្គ?

ខ ៨
តើព្រះបន្ទូលរបស់ព្រះអម្ចាស់ប្រាប់យ៉ាងដូចម្ដេចអំពីការឆ្លើយតបរបស់មនុស្សចំពោះព័ន្ធកិច្ចនៅពេលអនាគតរបស់លោកយេរេមា?
តើមានការលើកទឹកចិត្តអ្វី ដើម្បីឲ្យលោកយេរេមាប្រឈមមុខនឹងខ្មាំងសត្រូវរបស់លោក?

ខ ៩
តើព្រះអម្ចាស់បាន«ដាក់»ព្រះបន្ទូលរបស់ព្រះអង្គនៅក្នុងលោកយេរេមាយ៉ាងដូចម្ដេច?

ខ ១០
តើលោកអ្នកគិតថា ឃ្លា«ដករំលើង រុះទម្លាក់ បំផ្លាញរំលំចុះ សង់ និងដាំ» មានន័យយ៉ាងដូចម្ដេច?
តើលោកអ្នកគិតថា មានអ្វីអំពីអត្តចរិតរបស់លោកយេរេមាដែលអនុញ្ញាតឲ្យលោកធ្វើតាមផែនការរបស់ព្រះជាម្ចាស់?

ខ ១២

តើលោកអ្នករកឃើញគោលការណ៍អ្វីនៅក្នុងខគម្ពីរនេះអំពីព្រះដែលធ្វើការនៅក្នុងព័ន្ធកិច្ចរបស់អ្នកដែលព្រះអង្គបានត្រាស់ហៅ?

ខ ១៦
តើខគម្ពីរនេះបង្ហាញប្រាប់យ៉ាងដូចម្ដេចអំពីចរិតរបស់ព្រះ សូម្បីតែនៅពេលដែលជាការជំនុំជម្រះប្រជារាស្ត្ររបស់ព្រះអង្គ?
តើព្រះជាម្ចាស់ទ្រង់សុចរិតឬទេ ក្នុងអ្វីដែលព្រះអង្គគ្រោងនឹងធ្វើដល់ប្រជារាស្ត្រនោះ? ហេតុអ្វី?

ខ ១៧
តើ«ការត្រៀមខ្លួន»របស់លោកយេរេមាមានចំណែកអ្វី?
តើលោកអ្នកគិតថា ហេតុអ្វីបានជាព្រះអម្ចាស់មានព្រះបន្ទូលឡើងវិញអ្វីដែលព្រះអង្គបានមានព្រះបន្ទូលកាលពីមុនរួចហើយ (ខ ៨)?

ខ ១៨
តើឃ្លា «ទីក្រុងត្រៀមដោយគ្រឿងចម្បាំង សសរដែក និងកំផែងលង្ហិន» មានសារៈសំខាន់ និងអត្ថន័យយ៉ាងដូចម្ដេច?
ហេតុអ្វីបានជាមនុស្សនៅក្នុងខ ១៨ ប្រឆាំងនឹងលោកយេរេមា ព្រមទាំងព្រះរាជសាររបស់លោកខ្លាំងម្ល៉េះ?
តើព្រះជាម្ចាស់ចម្រើនកម្លាំង និងរៀបចំប្រជារាស្ត្ររបស់ព្រះអង្គនៅសព្វថ្ងៃនេះយ៉ាងដូចម្ដេចដើម្បីឲ្យឈរសម្រាប់ព្រះអង្គ?

ខ ១៩
តើខគម្ពីរនេះបង្ហាញប្រាប់យ៉ាងដូចម្ដេចអំពីអត្តចរិត និងការប្ដូរផ្ដាច់របស់ព្រះចំពោះអ្នកដែលព្រះអង្គត្រាស់ហៅ?

# ការបញ្ចប់

តើបន្ទាប់ទៀតជាអ្វី?

ការណែនាំសម្រាប់អ្នកសម្របសម្រួល:

- ចូររំឭកឡើងវិញភារកិច្ចផែនការសកម្មភាពទាំងពីរសម្រាប់ម៉ូឌុល ៥។
- ចូរសុំសិក្ខាកាមឲ្យរៀបរាប់គោលការណ៍ទាំង ៥ អំពីការផ្សាយដំណឹងល្អសម្រាប់អ្នកដាំក្រុមជំនុំ (សូមមើលម៉ោងទី ៣)។
- ចូរសុំសិក្ខាកាមឲ្យរៀបរាប់ទំនាក់ទំនងទាំងបីប្រភេទរវាងការបម្រើ និងការផ្សាយដំណឹងល្អ (សូមមើលម៉ោងទី ៥)។
- ចូរសុំសិក្ខាកាមឲ្យចែកចាយសេចក្ដីដែលពួកគេរៀនបាននៅក្នុងការហ្វឹកហ្វឺននេះ ដែលធ្វើឲ្យពួកគេរំភើបចិត្ត និងលើកទឹកចិត្តពួកគេសម្រាប់ការងាររបស់ពួកគេក្នុងនាមជាអ្នកដាំក្រុមជំនុំ។
- ចូរឲ្យសិក្ខាកាមកំណត់គោលដៅដាំក្រុមជំនុំសម្រាប់ខែនេះ (សូមមើលតារាងខាងក្រោម)។
- ចូរច្រៀងចម្រៀងថ្វាយបង្គំមួយបទជាមួយគ្នា ហើយបញ្ចប់ដោយការអធិស្ឋានសុំព្រះសម្រាប់អ្នកដាំក្រុមជំនុំទាំងនេះ។

មុនពេលដែលលោកអ្នកមករៀនម៉ូឌុលបន្ទាប់ទៀត យើងផ្ដល់យោបល់ឲ្យលោកអ្នកធ្វើកិច្ចការខាងក្រោម:

- ➢ ចូរទាក់ទងមនុស្សថ្មីឲ្យបាន ១០ នាក់
- ➢ ចូរប្រាប់ដំណឹងល្អដល់មនុស្ស ៥ នាក់
- ➢ ចូរចាប់ផ្ដើមក្រុមតូចថ្មីមួយ

ផែនការសកម្មភាពសម្រាប់ម៉ូឌុល ៥: បញ្ជីត្រួតពិនិត្យ

- ➢ ចូរដឹកនាំការសិក្សាព្រះគម្ពីរអំពីការប្រោសឲ្យបានសុចរិត ហើយនាំយកនិយមន័យរបស់ពួកគេអំពីការប្រោសឲ្យបានសុចរិតមកវិញ (សូមមើលម៉ោងទី ១)។
- ➢ ចូរធ្វើផែនការមេសម្រាប់ការដាំក្រុមជំនុំ (សូមមើលម៉ោងទី ៣)។

| **គោលដៅដាំក្រុមជំនុំសម្រាប់ខែនេះ** | |
|---|---|
| បុគ្គល | |
| អ្នកថ្មីដែលបានទាក់ទង | ចំនួន |
| អ្នកជឿថ្មី | ចំនួន |
| អ្នកថ្មីដែលបានទទួលបុណ្យជ្រមុជ | ចំនួន |

| | |
|---|---|
| ទឹក | |
| អ្នកដឹកនាំថ្មីកំពុងទទួលការហ្វឹកហ្វឺន | ចំនួន |
| ក្រុមតូច | |
| ក្រុមតូចថ្មី | ចំនួន |
| អ្នកចូលរួមថ្មីនៅក្នុងក្រុម | ចំនួន |
| អ្នកដឹកនាំថ្មីដែលមានក្រុមតូចមួយ | ចំនួន |